សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការតម្កល់រឿងទុកឥតចាត់ការ

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា សេត ចន្ធី**
**កញ្ញា ហ៊ុន រដ្ឋាប្រាណី**

សាស្ត្រាចារ្យណែនាំ
**លោក ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សេត ចន្នី** និងនាងខ្ញុំឈ្មោះ **ហ៊ុន រដ្ឋាប្រាណី** ជានិស្សិតផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៧-២០២១ ជំនាន់ទី២១។

សូមសម្តែងនូវសេចក្តីអំណរគុណកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ

**លោកឪពុក រៀម សេត** **អ្នកម្តាយ ជឿន សាលីន**

**លោកឪពុក ឌុយ ចាន់ថុល** **អ្នកម្តាយ សួន ស៊ីយ៉េត**

ដែលបានផ្តល់នូវកំណើតដល់រូបយើងខ្ញុំ និងព្រមទាំងចិញ្ចឹមបីបាច់ថែរក្សា តាំងពីចាប់កំណើតរហូតមកដល់ធំពេញវ័យ ពួកគាត់បានខិតខំប្រឹងប្រែង លះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្តដើម្បីទូន្មានប្រៀនប្រដៅប្រកបដោយគុណធម៌ ព្រមទាំងពុះពាររាល់គ្រប់ឧបសគ្គ ដើម្បីឱ្យកូនៗបានរៀនសូត្រមានចំណេះដឹងដើម្បីសងគុណដល់អ្នកមានគុណ និងបម្រើដល់សង្គមជាតិមាតុភូមិ។

**អង្គការ ការអប់រំច្បាប់សម្រាប់ស្ត្រីកម្ពុជា** (Cambodia Legal Education For Women) ហៅកាត់ថា CLEW ដែលបានឧបត្ថម្ភនូវអាហារូបករណ៍សម្រាប់ការសិក្សាផ្នែកនីតិសាស្ត្រ និងផ្តល់ជាកន្លែងស្នាក់នៅរយៈពេលបួនឆ្នាំពេញ និងការទំនុកបម្រុងផ្សេងៗទៀត។

**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រី សាស្ត្រាចារ្យ** ដែលបានផ្តល់នូវការអប់រំ ទាំងចំណេះដឹង និងដំបូន្មាន រួមទាំងការពន្យល់ណែនាំដល់ យើងខ្ញុំទាំងពីររហូតបានបញ្ចប់ការសិក្សាដោយជោគជ័យ។

**លោកសាស្ត្រាចារ្យ ហ៊ាង ឡេង** ដែលជាសាស្ត្រាចារ្យណែនាំ បានចំណាយពេលវេលា ដ៏មានតម្លៃក្នុងការពន្យល់ណែនាំ និងការកែលម្អរាល់ចំណុចខ្វះខាត នៃការសរសេរសារណានេះ តាំងពីដើមមក រហូតដល់យើងខ្ញុំទទួលបានលទ្ធផលជាស្ថាពរ។

ជាបញ្ចប់ក្រុមយើងខ្ញុំសូមប្រសិទ្ធិពរជ័យសិរីមង្គលជូនចំពោះ អ្នកមានគុណទាំងទ្វេ ឯកឧត្តម លោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ សូមឱ្យជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុៈ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ចំណេះដឹងពិតជាមានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ។ នៅក្នុងសង្គមបច្ចុប្បន្ន មិនអាចខ្វះបានឡើយនូវចំណេះជំនាញ ដើម្បីជាការដោះស្រាយជីវភាព ក៏ដូចជាជួយអភិវឌ្ឍន៍សង្គមជាតិ ឱ្យបានដំណើរការឆ្ពោះទៅមុខប្រកបដោយចីរភាព។ ចំណេះជំនាញរបស់មនុស្សម្នាក់ៗមានភាពខុសៗគ្នាទៅតាមចំណង់ចំណូលចិត្ត ក៏ដូចជាតម្រូវការផ្ទាល់ខ្លួន។ ជាក់ស្ដែងការសិក្សាលើមុខវិជ្ជានីតិសាស្ត្រ ដែលជាទូទៅគេស្គាល់ថាច្បាប់ ពោលគឺជាមុខវិជ្ជាដែលទូទាំងសកលលោកឱ្យតម្លៃ និងប្រើប្រាស់ជាប្រយោជន៍ក្នុងការដឹកនាំរដ្ឋ។ ប្រទេសជាតិមួយខ្លាំងក្លាទៅបាន គឺដោយសារមានគ្រឹះនីតិរដ្ឋដ៏រឹងមាំ។ ហេតុដូចនេះហើយ នៅក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលបានខិតខំប្រឹងប្រែង យ៉ាងសន្ធឹកសន្ធាប់ក្នុងដំណើរការជំរុញលើវិស័យនីតិសាស្ត្រ ជាពិសេសក្រសួងយុត្តិធម៌បានចាប់ផ្ដើមកែប្រែ ទៅលើប្រព័ន្ធនីតិវិធីព្រហ្មទណ្ឌចាប់តាំងពី ឆ្នាំ១៩៩៤ រហូតដល់ ឆ្នាំ១៩៩៨ និងឈានដល់ការរៀបចំគោលនយោបាយកំណែទម្រង់ប្រព័ន្ធច្បាប់នានាជាច្រើនទៀត។

ជាលទ្ធផល បានបង្ហាញឱ្យឃើញថា ការតស៊ូខិតខំប្រឹងប្រែងស្រាវជ្រាវសិក្សាកន្លងមក ពិតជាទទួលបានផ្លែផ្កាគួរជាទីគាប់ចិត្ត ពោលគឺយើងខ្ញុំអាចឈានដល់ ការសរសេរសារណា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៧-២០២១។ យើងខ្ញុំពិតជា មានមោទនភាពយ៉ាងក្រៃលែង ព្រមទាំងបានឆ្លងកាត់នូវបទពិសោធន៍ថ្មីៗ ក៏ដូចជាការលំបាកនានាអំឡុងពេលស្រាវជ្រាវ ដោយសារតែបញ្ហា ស្ថិតនៅក្នុងស្ថានភាព ជំងឺកូវីដ១៩ ធ្វើឱ្យការស្រាវជ្រាវមិនមានឯកសារគ្រប់គ្រាន់ក្នុងការបំពេញបន្ថែមនូវចំណុចខ្វះខាត។ ក៏ប៉ុន្តែឧបសគ្គទាំងនេះ រឹតតែធ្វើឱ្យយើងខ្ញុំមានភាពរឹងមាំ និងអាចយកមកអភិវឌ្ឍន៍ចំណេះដឹងខ្លួនឯងកាន់តែមានភាពប្រសើរឡើងមួយកម្រិតទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១៖
## សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

**ផ្នែកទី១៖ និយមន័យនៃការតម្កល់រឿងទុកឥតចាត់ការ** ........ ៣

**ផ្នែកទី២៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ** ........ ៤

កថាខណ្ឌទី១៖ ការតម្កល់រឿងទុកឥតចាត់ការលើអំពើដែលមិនមែនជាបទល្មើស ........ ៤

១. អវត្តមាននៃបទល្មើស ........ ៤

២. កង្វះធាតុផ្សំនៃបទល្មើស ........ ៤

២.១. ធាតុនីត្យានុកូល ឬធាតុច្បាប់ ........ ៥

២.២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ ........ ៥

២.៣. ធាតុអត្តនោម័ត ........ ៥

កថាខណ្ឌទី២៖ ការតម្កល់រឿងទុកឥតចាត់ការលើអំពើដែលជាបទល្មើស ........ ៦

១. កង្វះអត្តសញ្ញាណរបស់ជនល្មើស ........ ៦

២. បទល្មើសដែលមានព្យសនកម្មតិចតួច ........ ៧

៣. មូលហេតុគតិយុត្តិ ........ ៨

៣.១. អភ័យឯកសិទ្ធិ ........ ៨

៣.២. អនិយ័តភាពនៃនីតិវិធី ........ ៩

៣.៣. ការផុតរលត់នៃបណ្តឹងអាជ្ញា ........ ១០

ក. មរណភាពនៃជនល្មើស ........ ១០

ខ. ការផុតអាជ្ញាយុកាល ........ ១០

គ. ការលើកលែងទោសជាទូទៅ ........ ១១

ឃ. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ........ ១២

ង. អាជ្ញាអស់ជំនុំ ........ ១២

៤. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ១៣

៤.១. ជនវិបល្លាសស្មារតី ........ ១៣
៤.២. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ........ ១៣
៤.៣. ការការពារស្របច្បាប់ ........ ១៤
៤.៤. សច្ចធារណ៍នៃការការពារស្របច្បាប់ ........ ១៥
៤.៥. ស្ថានភាពចាំបាច់ ........ ១៥
៤.៦. អានុភាពនៃកម្លាំង ឬការបង្ខំ ........ ១៥
៤.៧. អ្នកប្រព្រឹត្តជាអនីតិជន ........ ១៥
៥. មូលហេតុផ្សេងទៀតនៃការរលត់នៃបណ្តឹងអាជ្ញា ........ ១៦
៥.១. ការសម្របសម្រួលជាមួយរដ្ឋ ........ ១៦
៥.២. ការដកពាក្យប្តឹងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ........ ១៧
៥.៣. ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល ........ ១៨
**ផ្នែកទី៣៖ សមត្ថកិច្ចក្នុងការតម្កល់រឿងទុកឥតចាត់ការស្ថាប័នអយ្យការ** ........ ១៩
កថាខណ្ឌទី១៖ ស្ថាប័នអយ្យការ ........ ១៩
១. រចនាសម្ព័ន្ធស្ថាប័នអយ្យការ ........ ១៩
១.១. អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ........ ២០
១.២. មហាអយ្យការអមសាលាឧទ្ធរណ៍ ........ ២០
១.៣. មហាអយ្យការអមតុលាការកំពូល ........ ២២
២. តួនាទីរបស់តំណាងអយ្យការ ........ ២៣
២.១. គោលការណ៍របស់តំណាងអយ្យការ ........ ២៤

## ជំពូកទី២៖

## នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

**ផ្នែកទី១៖ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ** ........ ២៥
កថាខណ្ឌទី១៖ ការទទួលពាក្យបណ្តឹង ........ ២៥
កថាខណ្ឌទី២៖ ការស៊ើបអង្កេតបឋម ឬស្រាវជ្រាវបន្ថែម ........ ២៥
កថាខណ្ឌទី៣៖ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ........ ២៦

កថាខណ្ឌទី៤៖ ការជូនដំណឹងដល់ភាគីដើមបណ្តឹង ............ ២៦
**ផ្នែកទី២៖ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ** ............ ២៧
កថាខណ្ឌទី១៖ អានុភាពគ្មានអាជ្ញាអស់ជំនុំទៅលើបណ្តឹងអាជ្ញា ............ ២៧
កថាខណ្ឌទី២៖ ផ្តើមគិតចិរវេលាអាជ្ញាយុកាលនៃបទល្មើសជាថ្មី ............ ២៧
កថាខណ្ឌទី៣៖ ការរួចផុតពីការចោទប្រកាន់ ............ ២៧
កថាខណ្ឌទី៤៖ ការទាមទារវត្ថុដែលរឹបអូសមកវិញ ............ ២៧
**ផ្នែកទី៣៖ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ** ............ ២៨
កថាខណ្ឌទី១៖ ការសើរើសេចក្តីសម្រេចរបស់តំណាងអយ្យការ ............ ២៨
កថាខណ្ឌទី២៖ ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ............ ២៨
១. នីតិវិធីនៃការដាក់ពាក្យប្តឹងតវ៉ា ............ ២៩
២. ចំណាត់ការលើបណ្តឹងតវ៉ា ............ ២៩
កថាខណ្ឌទី៣៖ ការធ្វើអធិបញ្ញាតាមនាយឋានានុក្រមនៃអង្គការអយ្យការ ............ ២៩
១. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ............ ២៩
២. អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ............ ៣០
៣. ព្រះរាជអាជ្ញាអមសាលាដំបូង ............ ៣០
៣.១. អំណាចនៃអធិបញ្ញា ............ ៣០
ក. ខ្លឹមសារ និងទម្រង់នៃអំណាចអធិបញ្ញា ............ ៣០
កថាខណ្ឌទី៤៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ............ ៣១
**ផ្នែកទី៤៖ ផលវិបាកនៃការតម្កល់រឿងទុកឥតចាត់ការ** ............ ៣១
កថាខណ្ឌទី១៖ គុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការ ............ ៣១
កថាខណ្ឌទី២៖ គុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការ ............ ៣២
**សេចក្តីសន្និដ្ឋាន** ............ ៣៤
**អនុសាសន៍** ............ ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមានគោលការណ៍នៃការចោទប្រកាន់២(ពីរ)គឺគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និងគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

ដោយគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ត្រូវបានយកមកប្រើប្រាស់ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ នៅពេលមានបទល្មើសកើតឡើងព្រះរាជអាជ្ញា ត្រូវតែធ្វើការប្តឹងចោទប្រកាន់ ដោយមិនគិតថាជារឿងតូចតាច ឬមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមតិចតួចនោះទេ ឱ្យតែមានបទល្មើសកើតឡើងព្រះរាជអាជ្ញាត្រូវធ្វើការប្តឹងចោទប្រកាន់ទាំងអស់។ ហើយព្រះរាជអាជ្ញាគ្មានសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការនោះទេ។

គោលការណ៍នេះគឺ គ្មានការរំលោភបំពានច្បាប់ក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួននោះទេ ដោយសារព្រះរាជអាជ្ញាប្រកាន់យកគោលការណ៍អព្យាក្រឹត្យ និងឯករាជ្យ ដោយមិនរណបទៅនឹងអង្គការណាមួយឡើយ។ ក៏ប៉ុន្តែគោលការណ៍នេះមិនផ្តល់ពេលគ្រប់គ្រាន់ក្នុងការស្វែងរកភស្តុតាង និងធ្វើឱ្យមានភាពយឺតយ៉ាវ ដោយសារមានការកកស្ទះសំណុំរឿង។ ដោយសារតែមូលហេតុបែបនេះ ទើបបានជានាំឱ្យមានគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

ចំពោះគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ ត្រូវបានយកមកប្រើប្រាស់ក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌសម័យបច្ចុប្បន្ន។ ហើយព្រះរាជអាជ្ញាមានសិទ្ធិពិចារណា ក្នុងការសម្រេចថាគួរធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ដោយអំណាចឆន្ទានុសិទ្ធិរបស់តំណាងអយ្យការ ទើបមិនមានការកកស្ទះសំណុំរឿងនៅក្នុងតុលាការ។ តែក៏អាចមានការរំលោភអំណាចក្នុងការប្រើប្រាស់សម្រាប់ ផលប្រយោជន៍ផ្ទាល់ខ្លួនផងដែរទៅលើការតម្កល់រឿងណាមួយទុកឥតចាត់ការ។

ដោយសារតែមាន គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់នេះហើយ ទើបបណ្តាលឱ្យតំណាងអយ្យការ មានសិទ្ធិអំណាចគ្រប់គ្រាន់ ក្នុងការថ្លឹងថ្លែងទៅលើសំណុំរឿង ដើម្បីសម្រេចតម្កល់ទុកឥតចាត់ការបាន។ ទោះបីជាមិនមាន ច្បាប់ចែងច្បាស់លាស់អំពីមូលហេតុជាក់លាក់ នៃការតម្កល់រឿងទុកឥតចាត់ការក៏ដោយ ក៏ព្រះរាជអាជ្ញាអាចប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនបានដែរ ទាំងអំពើដែលជាបទល្មើស និងអំពើដែលមិនមែនជាបទល្មើស។

មូលហេតុដែលបណ្តាលឱ្យមាន ការស្រាវជ្រាវទៅលើប្រធានបទ "ការតម្កល់រឿងទុកឥតចាត់ការ" ដើម្បីជាការពិភាក្សាទៅលើ គោលការណ៍ដែលព្រះរាជអាជ្ញាយកមកអនុវត្ត និងនីតិវិធីឱ្យបានច្បាស់លាស់ ដើម្បីទុកជាឯកសារសម្រាប់ការសិក្សាស្វែងយល់របស់អ្នកសិក្សាផ្នែកនីតិសាស្ត្រផងដែរ។ មួយវិញទៀតដោយមើលឃើញពីអំណាចអធិបញ្ញា របស់ក្រសួងយុត្តិធម៌មកលើស្ថាប័នអយ្យការ ទើបធ្វើឱ្យយើងខ្ញុំចង់ដឹងកាន់តែច្បាស់ថា

តើការតម្កល់រឿងទុកឥតចាត់ការមានន័យដូចម្តេច? តើមូលហេតុអ្វីខ្លះដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ? តើការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាទៅលើបទល្មើស មានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះដល់សង្គមជាតិទាំងមូល? តើស្ថាប័នណាខ្លះដែលមានតួនាទីក្នុងការធ្វើការតម្កល់រឿងទុកឥតចាត់ការ? តើនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការមានអ្វីខ្លះ? តើមានយន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការដែរឬទេ? ដោយមើលឃើញចំណុចទាំងនេះហើយ ទើបយើងខ្ញុំសម្រេចលើកយកប្រធានបទនេះមកស្រាវជ្រាវ អមជាមួយក្តីសង្ឃឹមថា នឹងអាចទទួលបាននូវ ចំណេះដឹងជាច្រើនទាំងផ្នែកច្បាប់ បទដ្ឋានគតិយុត្ត និងទ្រឹស្តីនានាពីការស្រាវជ្រាវមួយនេះ។

ប្រធានបទនេះមាន វិសាលភាពទៅលើរឿងក្តីព្រហ្មទណ្ឌ ដោយពាក់ព័ន្ធទៅនឹងចំណាត់ការរបស់ តំណាងអយ្យការ ក្នុងការត្រួតពិនិត្យ ថ្លឹងថ្លែង ទៅលើរឿងក្តីព្រហ្មទណ្ឌ ថាសម្រេចតម្កល់រឿងទុកឥតចាត់ការ និងបំពេញទៅតាមលក្ខខណ្ឌនៃ ការតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកទៅតាមអំណាចឆន្ទានុសិទ្ធិរបស់តំណាងអយ្យការ។

ដើម្បីជាការបកស្រាយទៅលើ ការស្រាវជ្រាវប្រធានបទ ការតម្កល់រឿងទុកឥតចាត់ការ ឱ្យកាន់តែលម្អិតថែមទៀត ប្រធានបទនេះត្រូវបានចែកចេញជាពីរជំពូក។ ជំពូកទី១ សិក្សាលម្អិតទៅលើ សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ រីឯជំពូកទី២រៀបរាប់អំពីនីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ព្រមទាំងបញ្ហាប្រឈម និងដំណោះស្រាយក្នុងការតម្កល់រឿងទុកឥតចាត់ការផងដែរ ដើម្បីជាការឆ្លើយតបទៅនឹងប្រធានបទឱ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត។

# ជំពូកទី១៖

# សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

# ជំពូកទី១៖
# សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ អង្គការអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា សិទ្ធិអំណាចរបស់តំណាងអយ្យការជារបស់ព្រះរាជអាជ្ញា ក្នុងការធ្វើចំណាត់ការលើបណ្តឹងអាជ្ញា ដែលជាជម្រើសនៃការចោទប្រកាន់កើតចេញពី គោលការណ៍នៃការចោទប្រកាន់តាមបែបកាលានុវត្តភាព ដែលជាការផ្តល់ជម្រើសដល់ព្រះរាជអាជ្ញាសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់ដោយការពិចារណា។ ក្រោយពីបានបោះបង់គោលការណ៍ចោទប្រកាន់តាមបែបនីត្យានុកូលភាព ដែលជាគោលការណ៍ឱ្យតែជាបទល្មើសត្រូវតែ ធ្វើការចោទប្រកាន់ទាំងអស់។ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺដើម្បីឱ្យព្រះរាជអាជ្ញាអាចថ្លឹងថ្លែងអំពីចំណាត់ការពាក្យបណ្តឹងដែលទទួលបានដោយផ្ទាល់ ឬពីមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ដោយសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។[1] ប៉ុន្តែចំពោះការសម្រេចធ្វើការតម្កល់រឿងទុកឥតចាត់ការ របស់ព្រះរាជអាជ្ញាទៅលើរឿងក្តី មានន័យថារឿងក្តីនោះត្រូវបានបញ្ចប់ទេ ព្រោះតែការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំឡើយ[2] ដូចនេះស្ថាប័នអយ្យការមានសិទ្ធិ កែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើងវិញក្នុងខណៈដែល បណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ[3] ដោយសេចក្តីសម្រេចនៃការតម្កល់រឿងទុកឥតចាត់ការនេះ ត្រូវធ្វើឡើងដោយផ្អែកលើ សំអាងច្បាប់ និងសំអាងហេតុ។[4]

## ផ្នែកទី១៖ និយមន័យនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ គឺជាសេចក្តីសម្រេចរបស់តំណាងអយ្យការ តាមគោលការណ៍ការលានុវត្តភាពនៃការចោទប្រកាន់ ដែលមានព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញា និងអនុវត្តបណ្តឹងអាជ្ញាជាទូទៅដើម្បីផលប្រយោជន៍សាធារណៈ និងមានតួនាទីក្នុងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[5] ព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការចោទប្រកាន់ ឬតម្កល់ទុកឥតចាត់ការបាន មុននឹងសម្រេចការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម[6] ទៅលើអំពើដែលជាបទល្មើស និងអំពើដែលមិនមែនជាបទល្មើសផងដែរ។

---

[1] មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[2] មាត្រា៤១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[3] មាត្រា៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[4] មាត្រា៤១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[5] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[6] មាត្រា៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ផ្នែកទី២៖ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

### កថាខណ្ឌទី១៖ ការតម្កល់រឿងទុកឥតចាត់ការលើអំពើដែលមិនមែនជាបទល្មើស

បទល្មើសព្រហ្មទណ្ឌត្រូវមានធាតុផ្សំបីគឺ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងអត្តនោម័ត។ យោងទៅតាមគោលការណ៍នីត្យានុកូលភាព អំពើដែលជាបទល្មើស គឺជាអំពើទាំងឡាយណាដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ហើយអាចប្រកាសបាននៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត និងចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌចូលជាធរមាន។[7] ចំពោះអំពើដែលមិនមានចែង មានន័យថាមិនមានបទល្មើសឡើយ ហើយមិនត្រូវបានផ្តន្ទាទោសទេ។ នៅពេលដែលបទល្មើសមួយមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ រួមទាំងច្បាប់មិនមានចែងទុកជាមុន តំណាងអយ្យការមានសិទ្ធិសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។ ដូចនេះអំពើដែលមិនមែនជាបទល្មើស ជាអំពើទាំងឡាយណាដែលច្បាប់មានចែងជាធរមាន ដោយសារតែអវត្តមាននៃបទល្មើស និងកង្វះធាតុផ្សំនៃបទល្មើស។

#### ១. អវត្តមាននៃបទល្មើស

បទល្មើស គឺជាអំពើរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលបង្កភាពចលាចលដល់សង្គម[8] ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។ ប៉ុន្តែក្នុងករណីដែលតំណាងអយ្យការ បានធ្វើការថ្លឹងថ្លែងទៅលើបណ្តឹងដែលទទួលបានពីមន្ត្រីនគរបាល ឬទទួលបានដោយផ្ទាល់ក្តី និងបានធ្វើការស៊ើបអង្កេត ស្រាវជ្រាវបានបង្ហាញថាអំពើនោះមិនមានកំណត់ដោយ បទប្បញ្ញត្តិច្បាប់ជាធរមានទេ ឬមិនមែនជាប្រភេទរឿងក្តីព្រហ្មទណ្ឌទេ តំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន។ ទោះបីជាអំពើខ្លះបានធ្វើឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍សណ្តាប់ធ្នាប់សាធារណៈក្តី ក៏មិនអាចចោទប្រកាន់បានឡើយ ព្រោះតែមិនមានបទប្បញ្ញត្តិច្បាប់បានចែងពីអំពើល្មើសនោះ។ ប្រសិនបើបទល្មើសខ្លះមិនមានច្បាប់ចែង តែបង្កនូវព្យសនកម្មធ្ងន់ធ្ងរដល់សង្គម នោះសិទ្ធិអំណាចរបស់តុលាការជាអ្នកសម្រេចលើករណីនោះ។ ហេតុដូចនេះហើយ អវត្តមាននៃបទល្មើស សំដៅដល់សំណុំរឿង ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ចំពោះសំណុំរឿងដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌសំដៅលើកំហុសរដ្ឋប្បវេណីជាដើម កង្វះធាតុផ្សំនៃបទល្មើស និងសំណុំរឿងដែលតំណាងអយ្យការមិនធ្វើចំណាត់ការ។

#### ២. កង្វះធាតុផ្សំនៃបទល្មើស

យោងតាមគោលការណ៍ ដើម្បីចោទប្រកាន់ទៅលើអំពើល្មើសណាមួយបាន លុះត្រាតែមាននូវធាតុផ្សំនៃបទល្មើសមានដូចជា ធាតុនីត្យានុកូល ឬធាតុច្បាប់ ធាតុសន្យានុម័ត ឬធាតុសម្ភារៈ និងធាតុអត្តនោម័ត។

---

[7] មាត្រា៣ នៃក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[8] មាត្រា២ នៃក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

អំពើល្មើសដែលបានប្រព្រឹត្តរួចហើយ ប៉ុន្តែមិនមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដូចបានរៀបរាប់ទាំងបីខាងលើ មិនអាចសម្រេចធ្វើការចោទប្រកាន់បានទេ ដោយធាតុផ្សំនៃបទល្មើសនេះផងដែរ ជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងគោលការណ៍ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើស និងមូលដ្ឋានចោទប្រកាន់សម្រាប់ព្រះរាជអាជ្ញាផងដែរ។ តំណាងអយ្យការមិនអាចសម្រេចធ្វើការចោទប្រកាន់បានទេប្រសិនបើខ្វះធាតុផ្សំណាមួយក្នុងចំណោមធាតុផ្សំទាំងបី ទោះបីជាអំពើនោះជាបទល្មើស ដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ពិសេសក្តី។

### ២.១. ធាតុនីត្យានុកូល ឬធាតុច្បាប់

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើណាមួយដែលប្រព្រឹត្តដោយចារីផ្ទាល់ សហចារី ឬជនសមគំនិតហើយត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ប្រសិនបើច្បាប់មិនមានចែងអំពើនោះជាបទល្មើសទេ នោះមិនត្រូវបានគេចាត់ទុកថាជាបទល្មើសបានទេ ហើយអាចប្រកាសទោសបានលុះត្រាតែបទល្មើសត្រូវបានប្រព្រឹត្ត និងមានបញ្ញត្តិព្រហ្មទណ្ឌជាធរមាន។[9] ដូចនេះគ្មានអំពើណាមួយដែលអាចកំណត់បទល្មើស ដោយគ្មានច្បាប់ចែងទេ។

### ២.២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ

ធាតុសត្យានុម័ត ឬធាតុសម្ភារៈ សំដៅដល់សកម្មភាពនៃការប្រព្រឹត្តិបទល្មើសពិតប្រាកដ ឬជាការប៉ុនប៉ងដែលជាការកំណត់ទៅលើបទល្មើសមួយដោយស្តែងចេញពីសកម្មភាពរបស់ជនល្មើស ទីកន្លែងនៃការប្រព្រឹត្តិបទល្មើស ហេតុផលដែលបណ្តាលឱ្យមានការប្រព្រឹត្តិល្មើស ឧបករណ៍ ឬវត្ថុដែលទទួលបានមកពីការប្រព្រឹត្តិបទល្មើសនោះ ឬផលប៉ះពាល់ដោយសារតែអំពើដែលបានប្រព្រឹត្តល្មើស ទៅលើទ្រព្យសម្បត្តិរដ្ឋ ឬទ្រព្យសម្បត្តិឯកជន បូរណភាពរបស់បុគ្គល និងសិទ្ធិសេរីភាពជាដើម។ ទាំងអស់នេះហើយដែលជាធាតុរបស់អំពើក្នុងការប្រព្រឹត្តិបទល្មើស។

### ២.៣. ធាតុអត្តនោម័ត

ធាតុអត្តនោម័ត សំដៅដល់ចេតនា ឬកំហុសរបស់ជនល្មើសក្នុងការប្រព្រឹត្តិបទល្មើស។ ជនល្មើសមានចេតនា និងបំណងក្នុងការបង្កជាភាពចលាចល ដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សុខសុវត្ថិភាពសង្គមក្នុងឆន្ទៈបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។ ជាគោលការណ៍មិនមានបទល្មើសកើតឡើងទេប្រសិនបើគ្មានឆន្ទៈ ឬគ្មានចេតនាក្នុងការប្រព្រឹត្តិបទល្មើស លើកលែងទៅលើបទល្មើសដែលកើតឡើងដោយការធ្វេសប្រហែស ការខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬការមិនគោរពកាតព្វកិច្ច ក្នុងករណីច្បាប់បានបញ្ញត្តិទុកជាមុន។[10] ហេតុដូចនេះហើយ អំពើប្រព្រឹត្តដែលកើតចេញពីជនដែលមិនមានឆន្ទៈក្នុងការប្រព្រឹត្តិ ឬគ្មាន

[9] មាត្រា៣ នៃក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

[10] មាត្រា៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ចេតនាទុច្ចរិតក្នុងការប្រព្រឹត្តិទេ មិនអាចធ្វើការចោទប្រកាន់បានទេ លើកលែងតែមានករណីដែលច្បាប់បានចែង អំពីកំហុសដោយចេតនាក្នុងការប្រព្រឹត្តិប៉ុណ្ណោះ ទើបត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

ជារួមមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ ទៅលើអំពើដែលបានប្រព្រឹត្តណាមួយថាជាបទល្មើសលុះត្រា តែបានបំពេញលក្ខខណ្ឌទាំងបីខាងលើរបស់ធាតុផ្សំនៃបទល្មើស ដែលមានដូចជា ធាតុនីត្យានុកូល ឬធាតុច្បាប់ ធាតុសន្យានុម័ត ឬធាតុសម្ភារៈ និងធាតុអត្តនោម័ត។ នៅពេលដែលខ្វះធាតុផ្សំនៃបទល្មើសណាមួយ តំណាង អយ្យការដែលជាព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន។

**កថាខណ្ឌទី២៖ ការតម្កល់រឿងទុកឥតចាត់ការទៅលើអំពើដែលជាបទល្មើស**

ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បាន កាលណាអំពើល្មើសមួយ មានគ្រប់លក្ខខណ្ឌទាំងអស់ របស់ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដោយមានច្បាប់ចែងច្បាស់លាស់។ ដោយអាស្រ័យទៅលើគោលការណ៍ កាលានុវត្តភាពនៃការចោទប្រកាន់ ព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់ បានទៅលើអំពើល្មើសណាមួយដែលជាបទល្មើសព្រហ្មទណ្ឌ។ ថ្វីត្បិតតែច្បាប់មានចែងអំពីបទល្មើសក៏ពិតមែន ប៉ុន្តែក៏មានករណីខ្លះ ដែលមិនត្រូវបានធ្វើការចោទប្រកាន់ផងដែរ ដូចជាកាលៈទេសៈនៃការប្រព្រឹត្តិ។ ហេតុដែល បណ្ដាលឱ្យមានការប្រព្រឹត្តិ ផលដែលទាក់ទងនឹងបទល្មើសមិនបង្កព្យសនកម្មធ្ងន់ធ្ងរ និងភាពចលាចលដល់ សង្គមនោះទេ។ ហេតុដូចនេះហើយបើព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ក៏មិនបានផ្ដល់ផលអ្វីដល់សង្គម ដែលនាំ ឱ្យកើតមានឡើងនូវការតម្កល់រឿងទុកឥតចាត់ការ ដោយសារតែព្រះរាជអាជ្ញា បានធ្វើការស៊ើបអង្កេតបន្ថែម តែមិនអាចដឹងពីអត្តសញ្ញាណរបស់ជនល្មើស ឬបទល្មើសដែលបានបង្កនោះមានព្យសនកម្មតិចតួច ឬបណ្ដាល មកពីមូលហេតុគតិយុត្តិផងដែរ។

**១. កង្វះអត្តសញ្ញាណរបស់ជនល្មើស**

កង្វះអត្តសញ្ញាណរបស់ជនល្មើស ក៏ជាមូលហេតុដែលបណ្ដាលឱ្យតំណាងអយ្យការសម្រេចតម្កល់រឿង ទុកឥតចាត់ការបានដែរ នៅពេលដែលអត្តសញ្ញាណរបស់ជនល្មើស មិនអាចកំណត់បានដោយគ្មានសាវតាជាតិ របស់ជនល្មើស នៅក្នុងបទល្មើសមួយដែលបានកើតឡើងទេ។ តំណាងអយ្យការអាចធ្វើការសម្រេចតម្កល់រឿង ទុកឥតចាត់ការបាន ដោយប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្រោយពីបានទទួលបានការស៊ើបអង្កេតបឋម ឬការស្រាវជ្រាវបន្ថែមដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលស្ថិតនៅក្រោមការដឹកនាំ និងសម្របសម្រួលរបស់ ព្រះរាជអាជ្ញា។[11] បន្ទាប់ពីការស៊ើបអង្កេតមិនបានស្គាល់ពី អត្តសញ្ញាណរបស់ជនល្មើស ជាហេតុមិនអាចបញ្ជូន ទៅតុលាការដើម្បីជំនុំជម្រះដោយផ្ទាល់បាន និងនាំឱ្យខាតបង់ផលប្រយោជន៍ផងនោះព្រះរាជអាជ្ញាអាចសម្រេច

[11] មាត្រា៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បានថាគួរតម្កល់រឿងនោះទុកឥតចាត់ការ ឬក៏អត់។

ជាក់ស្តែងដូចជាករណី មានអំពើហិង្សាមួយកើតឡើងអំឡុងពេលកំពុងរាំធុងបាសនាពេលយប់ក្នុងភូមិមួយ។ ពេលមន្ត្រីនគរបាលយុត្តិធម៌បានចុះមកផ្ទាល់ធ្វើការស៊ើបអង្កេតបឋម ក្រោយពីបានសាកសួរក្នុងកន្លែងកើតហេតុ ជនបង្កគឺមិនមែនជាអ្នកក្នុងភូមិនោះទេ។ ដោយសារតែពេលកើតហេតុជាពេលយប់ផងនោះ ទើបបានជាមិនមានអ្នកស្គាល់ពីជនសង្ស័យ ព្រមទាំងព័ត៌មានផ្ទាល់ខ្លួន មកពីណា ស្នាក់នៅកន្លែងណាគឺមិនមានតម្រុយអ្វីទាក់ទងនឹងជនសង្ស័យឡើយ។ ករណីនេះបើសិនមន្ត្រីនគរបាលយុត្តិធម៌រកមិនឃើញអត្តសញ្ញាណរបស់ជនល្មើស ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបានស្របទៅតាមឆន្ទានុសិទ្ធរបស់ខ្លួន។

ចៅក្រមស៊ើបសួរអាចធ្វើការបញ្ជូនដីកាដំណោះស្រាយទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់បាន។ នៅក្នុងករណីដែលចៅក្រមស៊ើបសួរ អាចចេញដីកាលើកលែងការចោទប្រកាន់បានមានដូចជា៖[12]

- អំពើប្រព្រឹត្តនោះ មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។
- មិនស្គាល់ជនដែលប្រព្រឹត្តអំពើនោះ ។
- គ្មានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកទៅលើជនត្រូវចោទ។

### ២.បទល្មើសដែលមានព្យសនកម្មតិចតួច

តំណាងអយ្យការ អាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ក្រោយពីបានធ្វើការស្រាវជ្រាវឃើញអំពីស្ថានការណ៍ដែលបណ្តាលឱ្យមានបទល្មើសកើតឡើង កាលៈទេសៈនៃការប្រព្រឹត្ត ដែលចារីបានប្រព្រឹត្តផ្ទុយពីកិរិយាមាយាទ ឆន្ទៈរបស់ខ្លួន ក្នុងស្ថានភាពចំបាច់ណាមួយ និងទទួលស្គាល់ពីអំពើល្មើសរបស់ខ្លួន ហើយមិនបានបង្កព្យសនកម្មធ្ងន់ធ្ងរ ភាពចលាចល ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមសាធារណៈធ្ងន់ធ្ងរ។ ទោះបីជាបទល្មើសនោះមានគ្រប់ធាតុផ្សំដែលបង្ហាញថាជាបទល្មើសព្រហ្មទណ្ឌក្តី ក៏តំណាងអយ្យការអាច ធ្វើការសម្រេចមិនចោទប្រកាន់ទៅលើរឿងនោះបានដែរ។ ទោះបីជាតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើជនល្មើស ក៏មិនទទួលបានផលប្រយោជន៍អ្វីដល់សង្គមជាតិដែរ។

ជាក់ស្តែង បុរសក្រីក្រម្នាក់បានទៅលួចបាយគេមួយប្រអប់ដើម្បីឱ្យកូនៗរបស់គាត់បានហូប។ ដោយគាត់ជាបុរសពោះម៉ាយមានជម្ងឺប្រចាំកាយ និងទទួលបន្ទុកកូន២នាក់ ដោយសារតែជីវភាពរបស់គាត់ខ្វះខាតផង។ តាមរយៈការសិក្សាពីអង្គហេតុខាងលើ បុរសពោះម៉ាយបានប្រព្រឹត្តបទល្មើសលួច បើយោងតាមមាត្រា៣៥៣នៃក្រមព្រហ្មទណ្ឌ បានចែងអំពីនិយមន័យនៃអំពើលួច និងមាត្រា៣៥៦នៃក្រមព្រហ្មទណ្ឌ ដែលចែងអំពីទោស។ ដោយការប្រព្រឹត្តិល្មើសខាងលើនេះមានធាតុផ្សំគ្រប់គ្រាន់ ប៉ុន្តែប្រសិនបើយើងក្រឡេកទៅមើលលើមូលហេតុ

[12] មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

និងផលប្រយោជន៍ ដែលគាត់ទទួលបានពីការប្រព្រឹត្តិបទល្មើសនោះវិញគឺមានព្យសនកម្មតិចតួច និងដោយសារតែកត្តាជីវភាពរបស់គាត់រួមជាមួយភាពស្រេកឃ្លាន ដើម្បីបានអាហារផ្តល់ឱ្យកូនៗរបស់គាត់បានហូបផង។ ហេតុនេះហើយតំណាងអយ្យការ អាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការបាន។ ទោះបីជាធ្វើការចោទប្រកាន់ក៏មិនទទួលបានផលប្រយោជន៍អ្វីឡើយ មានតែធ្វើឱ្យកូនៗរបស់គាត់ គ្មានអាណាព្យាបាលក្លាយជាក្មេងកំព្រា មិនមានអ្នកចាំទំនុកបម្រុងគ្រួសារ ធ្វើឱ្យតុលាការមានបន្ទុកកាន់តែច្រើនក្នុងការដោះស្រាយ។

### ៣. មូលហេតុគតិយុត្ត

យោងទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មិនមានការអះអាងអំពីមូលហេតុច្បាស់លាស់ក្នុងការតម្កល់រឿងទុកឥតចាត់ការនោះទេ ដោយមានតែនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ។ ជាហេតុនាំឱ្យព្រះរាជអាជ្ញា ប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់ខ្លួន។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីការមិនចោទប្រកាន់ទៅលើបុគ្គលដែលមានអភ័យឯកសិទ្ធិ រួមទាំងមាត្រា៧ ចែងអំពីការរលត់នៃបណ្តឹងអាជ្ញា និងមាត្រា៨ ចែងអំពីមូលហេតុផ្សេងទៀតនៃការរលត់នៃបណ្តឹងអាជ្ញា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ តួយ៉ាងនៅក្នុងមាត្រា២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងអំពីការតម្កល់រឿងទុកឥតចាត់ការ ទៅលើអនីតិជនក្រោមអាយុ១៤ឆ្នាំ។ ដោយនេះជាមូលហេតុគតិយុត្តដែលមានចែងក្នុងច្បាប់ សម្រាប់ឱ្យតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់បាន។

#### ៣.១. អភ័យឯកសិទ្ធិ

អភ័យឯកសិទ្ធិ សំដៅលើការការពារទៅលើបុគ្គលដែលមានលក្ខណៈពិសេស ក្នុងការរួចផុតពីការចោទប្រកាន់។ តំណាងរាស្ត្រមានអភ័យឯកសិទ្ធិ មិនត្រូវបានធ្វើការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយសារតែការបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនទេ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិករដ្ឋសភាណាមួយអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពី រដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាក្នុងចន្លោះពេលប្រជុំសភា លើកលែងករណីដែលមានបទល្មើសព្រហ្មទណ្ឌជាក់ស្តែងបានកើតឡើង។[13] អភ័យឯកសិទ្ធិរដ្ឋសភា អភ័យឯកសិទ្ធិព្រឹទ្ធសភា អភ័យឯកសិទ្ធិការទូតបុគ្គលទាំងនេះត្រូវបានការពារដោយច្បាប់ចំពោះមុខងាររបស់ខ្លួន ក្នុងការបំពេញតួនាទីរបស់ខ្លួន ទោះបីជារកឃើញថាជាបទល្មើសក៏ដោយ តែមិនអាចធ្វើការចោទប្រកាន់បានឡើយ។

លើសពីនេះ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងអំពីអភ័យឯកសិទ្ធិដល់បុគ្គលដែលមិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌផងដែរ គឺអភ័យឯកសិទ្ធិគ្រួសារ ដែលមានចែងក្នុងមាត្រា៣៥៥

[13]មាត្រា៨០ នៃច្បាប់រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា អភ័យឯកសិទ្ធិគ្រួសារ សំដៅទៅលើភាពមិនអាចផ្ដន្ទាទោសព្រហ្មទណ្ឌបាន។ ចំពោះជនដែលបានប្រព្រឹត្តបទល្មើសលួច (អំពើលួចទ្រព្យសម្បត្តិ) បើជននោះលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ និងទ្រព្យសម្បត្តិរបស់សហព័ទ្ធខ្លួន។ បានពន្យល់ក្នុងសទ្ទានុក្រមនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ពាក្យ "បុព្វញាតិ" ជាជនដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន ពោលគឺ ជីដូនជីតា ឪពុកម្ដាយ មាមីង ឬន័យសាមញ្ញត្រូវបានហៅថា អ្នកជំនាន់មុន។ ពាក្យថា "បច្ឆាញាតិ" ជាជន ឬពួកជន ដែលកើតពីជនមួយពួកទៀត ពោលគឺ កូន ចៅ ក្មួយ ឬហៅថា អ្នកជំនាន់ក្រោយ។ រីឯពាក្យថា «សហព័ទ្ធ» គឺសំដៅទៅលើប្ដី ឬប្រពន្ធ ឬទាំងប្ដីទាំងប្រពន្ធ ដែលទទួលបានឋានៈជាសហព័ទ្ធនេះ ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

ក្នុងន័យនេះ បើមានករណីលួចទ្រព្យសម្បត្តិនៅក្នុងសង្គមគ្រួសារ ដែលប្រព្រឹត្តឡើងដោយបុព្វញាតិ ឬបច្ឆាញាតិ ក៏ដូចជាសហព័ទ្ធពិតមែន នោះមាត្រា៣៥៥ នៃក្រមព្រហ្មទណ្ឌមានអានុភាពអនុវត្ត ចំពោះករណីនេះ ដែលអាចឱ្យអ្នកប្រព្រឹត្តនោះ រួចផុតពីការផ្ដន្ទាទោស ចំពោះបទល្មើសលួចទ្រព្យសម្បត្តិ។ អភ័យឯកសិទ្ធិគ្រួសារនេះ មានបំណងបញ្ចៀសនូវរាល់ផលវិបាកទាំងឡាយ ដែលអាចកើតចេញពីរឿងក្ដីព្រហ្មទណ្ឌ នៅក្នុងរង្វង់គ្រួសារ។ គួរបញ្ជាក់ផងដែរថា អភ័យឯកសិទ្ធិគ្រួសារនេះ អាចអនុវត្តបានចំពោះតែបទល្មើសលួចតែប៉ុណ្ណោះ ដោយមិនគ្របដណ្ដប់លើស្ថានទម្ងន់ទោសឡើយ។

ជាក់ស្ដែងក្នុងករណី លោក **ក** បានលួចម៉ូតូដែលជាកម្មសិទ្ធិរបស់លោក **ខ** ត្រូវជាជីតារបស់ខ្លួនទៅលក់ដើម្បីយកទៅលេងល្បែង។ ចំពោះករណីនេះ តុលាការមិនអាចផ្ដន្ទាទោសលោក **ក** បានឡើយ។ ពីព្រោះលោក **ក** ត្រូវជាចៅ (បច្ឆាញាតិ) របស់លោក **ខ** ដែលត្រូវបានផ្ដល់អភ័យឯកសិទ្ធិតាមរយៈមាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

### ៣.២.អនិយ័តភាពនៃនីតិវិធី

អនិយ័តភាពនៃនីតិវិធីសំដៅដល់ ការអនុវត្តន៍នៅដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌ មិនត្រឹមត្រូវតាមច្បាប់កំណត់ នាំឱ្យព្រះរាជអាជ្ញាធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកទៅលើអំណាចឆន្ទានុសិទ្ធិ។ ដោយមន្ត្រីនគរបាលយុត្តិធម៌ ជាជំនួយរបស់អំណាចតុលាការ គឺជំនួយការរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ មានភារកិច្ចក្នុងការត្រួតពិនិត្យទៅលើ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដោយកំណត់ពីអត្តសញ្ញាណ និងចាប់ជនល្មើស រួមជាមួយនឹងការប្រមូលភស្តុតាងផងដែរ។[14] តួយ៉ាងក្នុងករណី ដែលមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការឃាត់ជនល្មើសខុសអត្តសញ្ញាណ ក្នុងដំណាក់កាលស៊ើបអង្កេតបឋម ដែលអ្នក

[14] មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ប្រព្រឹត្តពិតប្រាកដគឺ **ក** ប៉ុន្តែគាត់បែរជាឃាត់ខ្លួន **ខ** ហើយធ្វើកំណត់ហេតុបញ្ជូនខុសសាវតារបស់ជនល្មើសបញ្ជូនទៅព្រះរាជអាជ្ញា។ យោងទៅតាមមោឃភាពនៃការមិនគោរពតាមវិធាន និងទម្រង់នៃកំណត់ហេតុស្តីពីការឃាត់ខ្លួន ដែលមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនឹងនាំឱ្យមានមោឃភាពនៃនីតិវិធី។[15]

### ៣.៣. ការផុតរលត់នៃបណ្តឹងអាជ្ញា

ការផុតរលត់នៃបណ្តឹងអាជ្ញា អាចបណ្តាលមកពីការផុតអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា មរណភាពនៃជនល្មើស ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ អាជ្ញាអស់ជំនុំ។[16] ទាំងនេះជាមូលហេតុដែលព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការបាន កាលណាបណ្តឹងអាជ្ញាបានរលត់ ឬអស់អានុភាព។

#### ក. មរណភាពនៃជនល្មើស

បណ្តឹងអាជ្ញាត្រូវបានរលត់នៅពេលដែល ជនជាប់ចោទទទួលមរណភាព ក្នុងពេលដំណើរការរឿងក្តីព្រហ្មទណ្ឌប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការស្នើសុំសំណងរដ្ឋប្បវេណីបានជាមួយសន្តតិជនរបស់ជនល្មើសក្នុងការជួសជុលការខូចខាតពី សិទ្ធិវន្តរបស់ជនជាប់ចោទបាន ហើយតុលាការព្រហ្មទណ្ឌនៅតែមានសិទ្ធិសម្រេចក្នុងបណ្តឹងរដ្ឋប្បវេណីដើម្បីប្រឆាំង នឹងសិទ្ធិវន្តទាំងនោះ។[17]

#### ខ.ការផុតអាជ្ញាយុកាល

បណ្តឹងអាជ្ញាត្រូវបានរលត់ កាលណាអាជ្ញាយុកាលនៃបទល្មើសត្រូវបានរលត់ ហើយថិរវេលាគិតចាប់ពីពេលប្រព្រឹត្តបទល្មើស។ ប្រសិនបើបទល្មើសនោះបានកើតឡើងហើយ តែមិនមានការបើកការស៊ើបសួរ ឬការដាក់ពាក្យបណ្តឹងចោទប្រកាន់ពីជនរងគ្រោះទេ នោះអាជ្ញាយុកាលរាប់ពីថ្ងៃដែលកើតហេតុរហូតដល់ពេលដែលបានកំណត់។[18] ចំពោះបទល្មើសត្រូវបានចាប់ផ្តើមការស៊ើបសួរ ឬការចោទប្រកាន់ នោះអាជ្ញាយុកាលនៃបទល្មើសនឹងចាប់ផ្តើមពីពេល នៃការបើកស៊ើបសួរពីអង្គព្រះរាជអាជ្ញា ឬពេលដាក់ពាក្យបណ្តឹងពីជនរងគ្រោះរហូតដល់ពេលថិរវេលានៃអាជ្ញាយុកាលនីមួយៗ ដែលស្ថិតទៅលើប្រភេទនៃបទល្មើស ដោយថិរវេលានៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញាមានរយៈពេល ១៥(ដប់ប្រាំ)ឆ្នាំ ចំពោះបទឧក្រិដ្ឋ ៥(ប្រាំ)ឆ្នាំ ចំពោះបទមជ្ឈិម

[15] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[16] មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[17] មាត្រា២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[18] មាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

១(មួយ)ឆ្នាំ ចំពោះបទលហុ។[19] ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចរួចផុតអាជ្ញាយុកាលបានទេ[20]។

ករណីទី១៖ កញ្ញា **ក** ត្រូវបានគេរំលោភនៅកំឡុង ឆ្នាំ២០០០ ដោយមិនមានតម្រុយអ្វីអំពីជនសង្ស័យទាល់តែសោះ។ រហូតមកដល់ ឆ្នាំ២០១៨ មានសាក្សីបានចូលមកបំភ្លឺពីជនសង្ស័យ។ បន្ទាប់មកទើបមានការស៊ើបអង្កេត និងឈានទៅដល់ការចាប់ខ្លួនជនសង្ស័យ។ បទរំលោភសេពសន្ថវៈជាបទឧក្រិដ្ឋ បើយោងទៅតាមក្រមព្រហ្មទណ្ឌ មាត្រា២៣៩ កថាខណ្ឌទី២ បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ។ ដោយអាជ្ញាយុកាលនៃបទឧក្រិដ្ឋមានរយៈពេល ១៥(ដប់ប្រាំ)ឆ្នាំ គិតចាប់ពីពេលប្រព្រឹត្តបទល្មើស។

ករណីខាងលើនេះ ត្រូវបានចាប់ខ្លួន ជនសង្ស័យនៅឆ្នាំ២០១៨ ដែលបានកើតហេតុកាលពី ឆ្នាំ២០០០ ដែលមាន រយៈពេលកន្លងផុតទៅអស់ ១៨(ដប់ប្រាំបី)ឆ្នាំទៅហើយ។ ដូចនេះមិនអាចធ្វើការដាក់ទោសជនល្មើសបានឡើយ ដោយសារតែអាជ្ញាយុកាលនៃទោសត្រូវបានរលត់។

ករណីទី២៖ កញ្ញា **ខ** ត្រូវបានគេរំលោភនៅកំឡុង ឆ្នាំ២០០០ ដោយមិនមានតម្រុយអំពីជនសង្ស័យទាល់តែសោះ។ បន្ទាប់មកនៅក្នុង ឆ្នាំ២០០៦ ត្រូវបានបើកកាស៊ើបអង្កេតឡើងវិញម្តងទៀត ដោយមានអ្នកបានដឹងពីតម្រុយរបស់ជនសង្ស័យ ប៉ុន្តែមិនរកឃើញអ្វីទាក់ទងនឹងរឿងក្តីឡើយ។ ក្រោយមកទៀតនៅ ឆ្នាំ២០១៦ ក៏មានសាក្សីបង្ហាញពីជនសង្ស័យ ទើបបើកការស៊ើបអង្កេតម្តងទៀត និងចាប់បានជនសង្ស័យ។

ករណីនេះ បើគិតពីពេលប្រព្រឹត្តបទល្មើស មកដល់ពេលចាប់ខ្លួនជនល្មើសមានរយៈ១៦ឆ្នាំ កន្លងផុតទៅហើយ។ ប៉ុន្តែគេអាចដាក់ទោសទៅលើជនល្មើសបានដោយសារតែនៅឆ្នាំ២០០៦ មានការបើកការស៊ើបអង្កេតម្តងហើយ ទើបអាជ្ញាយុកាលនៃទោសបានគិតចាប់ពីពេល នៃការបើកការស៊ើបអង្កេតកាលពីឆ្នាំ២០០៦ មកទល់នឹង ឆ្នាំ២០១៦ មានរយៈពេល ១០(ដប់)ឆ្នាំ នៅសល់រយៈពេល ៥(ប្រាំ)ឆ្នាំ ទៀតទើបអាជ្ញាយុកាលនៃទោសត្រូវបានរលត់។ ករណីនេះជនល្មើសត្រូវតែទទួលទោសតាមច្បាប់ ដោយសារតែអាជ្ញាយុកាលនៃទោសមិនទាន់រលត់ ដោយសារតែមានការស៊ើបអង្កេតម្តងទៀតនៅពេលដែលមានតម្រុយអំពីជនល្មើស ដូចនេះអាជ្ញាយុកាលនៃទោសត្រូវចាប់ផ្តើមសារជាថ្មី ដោយគិតចាប់ពីពេលបើកការស៊ើបសួរម្តងទៀត។

### គ. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ គឺជាបទប្បញ្ញត្តិច្បាប់ដែលមានអានុភាពទៅលើការរលត់បណ្តឹងអាជ្ញា

[19] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[20] មាត្រា៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ទៅលើសកម្មភាពដែលបានប្រព្រឹត្តណាមួយ។ ការលើកលែងទោសជាទូទៅជាមូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀតក្នុងការរលត់នៃបណ្តឹងអាជ្ញាបើយោងទៅតាម មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌទី១ ចំណុចទី៣។ ការលើកលែងទោសជាទូទៅស្ថិតនៅក្រោមអំណាចរបស់នីតិប្បញ្ញត្តិ ដែលជ្រើសយកមតិភាគច្រើនរបស់រដ្ឋសភាជាអ្នកអនុម័ត។[21] អាចធ្វើការលើកលែងទោសជាទូទៅបានដោយផ្អែកទៅលើ ទោសប្រកាសដែលត្រូវបានលើកលែង គុណសម្បត្តិរបស់ជនល្មើស ប្រភេទនៃបទល្មើសដែលត្រូវបានទទួលការលើកលែងទោស។

ទោសប្រកាសដែលត្រូវបានលើកលែង អាចជាទោសដែលតុលាការបានប្រកាសពី ៣(បី)ខែ ដល់ ៣(បី)ឆ្នាំ។

គុណសម្បត្តិរបស់ជនល្មើសដែលមានអាយុក្រោម ២៥(ម្ភៃប្រាំ)ឆ្នាំ អាចធ្វើការស្នើសុំថ្វាយព្រះមហាក្សត្របានព្រះរាជក្រឹត្យធ្វើការលើកលែង នឹងសម្រេចនៅពេលដែលទទួលបានការសិក្សា អំពីករណីរបស់ចារីនៃបទល្មើសនោះ។

ប្រភេទបទល្មើស ដែលទទួលបានការលើកលែងទោស នៅពេលដែលបណ្តឹងអាជ្ញាបានរលត់នោះតុលាការមិនអាចសម្រេចផ្តន្ទាទោសបានទេ។ ចៅក្រមត្រូវធ្វើការប្រកាសទោសជាមុន ទើបអាចបញ្ជាក់ពីអត្រាទោសដែលអាចលើកលែងបានឬអត់។

### ឃ. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

កាលណាច្បាប់ត្រូវបានប្រកាសនិរាករណ៍ហើយយនោះ មានន័យថាបណ្តឹងអាជ្ញាក៏ត្រូវបានរលត់ដែរ ប្រសិនបើមានបទប្បញ្ញត្តិចាស់ ដែលមានចែងចំពោះបទល្មើសនោះថាត្រូវបាននិរាករណ៍។ ចំពោះច្បាប់ថ្មីដែលបានចូលជាធរមាន ក្រោយពីបទល្មើសដែលបានប្រព្រឹត្ត នោះបទល្មើសនោះមិនទទួលបានការចោទប្រកាន់ឡើយ។[22]

### ខ.អាជ្ញាអស់ជំនុំ

គោលការណ៍អាជ្ញាអស់ជំនុំ ត្រូវបានអនុវត្តទៅលើជនល្មើសដែល តុលាការបានសម្រេចឱ្យរួចខ្លួនហើយមិនត្រូវបានធ្វើការចោទប្រកាន់ទៀតទេ ទោះបីជាមានការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។[23] គោលការណ៍អាជ្ញាអស់ជំនុំ ជាគោលការណ៍ដែលរារាំងការដំណើរការ ទៅលើនីតិវិធីថ្មីចំពោះអំពើដូចគ្នា។ ការទាមទារការចោទប្រកាន់ដែលបានចោទ ត្រូវតែដូចគ្នាទៅនឹងបទល្មើស ដែលជនល្មើសបានសម្រេចឱ្យ

[21] មាត្រា៩០ (ថ្មី) នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣

[22] មាត្រា៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[23] មាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជាប់ទោស ឬការរួចផុតពីការចោទប្រកាន់។ ម្យ៉ាងទៀតគោលការណ៍នេះ អាចហៅបានថាជាគោលការណ៍គ្មានការកាត់ទោសពីរដងទៅលើបទល្មើសតែមួយ។ ផ្អែកទៅលើគោលការណ៍នេះមិនមានជនណាម្នាក់ត្រូវបានកាត់ទោសទៅលើ បទល្មើសណាដែលខ្លួនបានជាប់ទោស ឬរួចផុតពីបទដែលបានចោទរួចហើយនោះទេ។

**៤. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ**

គោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើដែលខ្លួនបានធ្វើប៉ុណ្ណោះ។[24] មិនអាចមានជនណាម្នាក់មកទទួលខុសត្រូវទោសកំហុសជំនួសអំពើល្មើសរបស់អ្នកដទៃបានឡើយ។ ច្បាប់ក៏មានអញ្ញត្តិកម្ម ដែលនាំឱ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ដោយមានមូលហេតុមួយចំនួនមានដូចជា វិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធារណ៍នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ អានុភាពនៃកម្លាំង ឬការបង្ខំ និង អនីតិជនដែលមានអាយុក្រោម១៤(ដប់បួន)ឆ្នាំ។

**៤.១. ជនវិបល្លាសស្មារតី**

ជនដែលមានវិបល្លាសស្មារតី គឺជាបុគ្គលដែលបាត់បង់សមត្ថភាព ក្នុងការទទួលដឹងខុសត្រូវទាំងស្រុង។ ដោយសារតែបុគ្គលដែលមានវិបល្លាសស្មារតី មិនអាចបែងចែកពីអំពើរបស់ខ្លួនដែលបានប្រព្រឹត្តនោះ ថាត្រូវ ឬខុសនោះទេ។ ទើបច្បាប់កំណត់ថាជនដែលបាត់បង់ការទទួលខុសត្រូវរបស់ខ្លួន គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែចំពោះជនដែលមានវិបល្លាសស្មារតី ដែលនាំឱ្យមានការកាត់បន្ថយការយល់ដឹងរបស់ខ្លួន បុគ្គលនោះនៅតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដដែល គ្រាន់តែទទួលបានការបន្ធូរបន្ថយទោសប៉ុណ្ណោះ។ ហើយត្រូវមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ពីគ្រូពេទ្យជំនាញ ដើម្បីឱ្យតុលាការធ្វើការពិនិត្យ ពិចារណាទៅលើសេចក្តីសម្រេចក្នុងការកំណត់ទោស។ ចំពោះបុគ្គលមួយចំនួនផ្សេងទៀតដែលជា បុគ្គលវិបល្លាសស្មារតី ដោយសារតែ សារធាតុញៀន សារជាតុស្រវឹង ឬសារធាតុផ្សេងៗដែលច្បាប់បានហាមឃាត់ គឺមិនត្រូវបានទទួលការលើកលែងទោសនោះទេ ឬមិនអាចចាត់ថាមិនមែនជាបទល្មើសនោះទេ។[25]

**៤.២. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ**

បុគ្គលដែលប្រព្រឹត្តអំពើដែលច្បាប់បានកំណត់ ឬតាមការបញ្ជារ របស់អាជ្ញាធរស្របច្បាប់ មិនចាត់ទុកជាការប្រព្រឹត្តិបទល្មើសនោះទេ។ ទោះបីជាអំពើនោះជាបទល្មើសក៏ដោយ ក៏មិនអាចចោទជាបទល្មើសដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ លើកលែងតែការប្រព្រឹត្តិនោះជាអំពើដែលផ្ទុយពីច្បាប់ដែលបានកំណត់ទុក ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត ក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

[24] មាត្រា២៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[25] មាត្រា៣១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ឬបទឧក្រិដ្ឋសង្គ្រាម ជាបទល្មើសមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានទេ។ ទោះបីជាជននោះបាន ប្រព្រឹត្តអំពើដែលច្បាប់មិនបានហាមឃាត់ ឬអំពើដែលប្រព្រឹត្តតាមការបញ្ជា របស់អាជ្ញាធរដែលស្របច្បាប់ក៏ដោយ។[26]

**៤.៣. ការការពារស្របច្បាប់**

បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវ ដោយមានការចាំបាច់ដើម្បីការពារខ្លួន គឺការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ដែលប្រឈមមុខនឹងការឈ្លានពានមួយមិនត្រឹមត្រូវ ជាការការពារដែលស្ថិតនៅក្នុងស្ថានភាពចំបាច់ ព្រោះតែបុគ្គលមួយចំនួនដែលបានទទួលរងនូវ អំពើឈ្លានពានមិនត្រឹមត្រូវ ដែលអាចបណ្តាលឱ្យមាននូវព្យសនកម្ម បាត់បង់ជីវិត ប៉ះពាល់ដល់បូរណភាពរូបកាយ ទ្រព្យសម្បត្តិ ឬប្រទេសជាតិជាដើម។ បើសិនជាមិនមានការការពារស្របច្បាប់ ការខូចខាតនោះមិនអាចកែប្រែឱ្យវិលមករកសភាពដើមវិញបានឡើយ។ ទោះបីជាអំពើដែលបានប្រព្រឹត្តទៅលើបុគ្គលណាម្នាក់នោះ មិនមែនជាអំពើដែលជាបទល្មើសដែលច្បាប់បានកំណត់ ឬការប្រព្រឹត្តិនៃអំពើនោះដោយអនីតិជន ឬជនដែលមានវិបល្លាសស្មារតីក៏ដោយ ក៏បុគ្គលនោះមានសិទ្ធិក្នុងការការពារស្របច្បាប់ដែរ។ បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា ដោយអំពើល្មើសត្រូវតែកើតឡើងមុនការការពារស្របច្បាប់ បើសិនជាមិនមានការប្រព្រឹត្តិអំពើល្មើសមុនទេ នោះមិនមានការការពារ ស្របច្បាប់នោះទេ។ បើសិនជាបុគ្គលនោះសំអាងថាការការពារបានកើតមុនអំពើល្មើសនោះ គឺជាការបំពានដែលច្បាប់បានកំណត់ ត្រូវទទួលទោស ព្រោះមិនមែនជាការការពារដែលស្របច្បាប់នោះទេ។ ប្រសិនបើការការពារនោះមានរយៈពេលមិនសមាមាត្រគ្នា ដោយគម្លាតរយៈពេលនៃការប្រព្រឹត្តិបទល្មើស ដែលបានកើតឡើងបានបញ្ចប់ហើយ ទើបមានការការពារនោះមិនមែនជាការការពារស្របច្បាប់នោះទេ តែជាការសងសឹកទៅវិញ បុគ្គលនោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ការការពារស្របច្បាប់ត្រូវតែគ្មានវិសមាមាត្រគ្នា រវាងមធ្យោបាយការពារដែលប្រើប្រាស់ដើម្បីតបត និងទម្ងន់នៃការឈ្លានពាន។ ការការពារនោះផងដែរ អាចធ្វើការតបតដោយសមត្ថភាពផ្ទាល់ ដូចជា តបតដោយប្រើប្រាស់ដៃជើង ឬការការពារដោយប្រើប្រាស់អាវុធដូចជា វត្ថុ សត្វ ឬឧបករណ៍ដើម្បីបង្កជារបួសស្នាម ឬសម្លាប់ ទៅតាមទំហំនៃការឈ្លានពាននោះ ឬការប្រើប្រាស់អាវុធរបស់ជនល្មើស។ ការការពារស្របច្បាប់ទាំងនេះ ច្បាប់បានអនុញ្ញាតឱ្យ បុគ្គលណាដែលប្រព្រឹត្តបទល្មើស ក្នុងសភាពការការពារស្របច្បាប់ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ។[27]

---

[26] មាត្រា៣២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[27] មាត្រា៣៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

### ៤.៤.សច្ចធារណ៍នៃការការពារស្របច្បាប់

សច្ចធារណ៍ គឺជាការសន្មត់នៃការការពារស្របច្បាប់ ដែលមាននៅក្នុងករណី បទល្មើសដែលបានប្រព្រឹត្តនោះកើតឡើងដោយហិង្សា កាប់គាស់ទម្លុះ ឬប្រើប្រាស់ល្បិចកល នៅទីកន្លែងដែលមានមនុស្សនៅដើម្បីប្រព្រឹត្ត បទល្មើស ឬការពារខ្លួនដើម្បីប្រឆាំងទៅនឹងបទល្មើសលួច ឬប្លន់ដោយការប្រើហិង្សា។ ប៉ុន្តែសច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតនោះទេ មានន័យថាសច្ចធារណ៍នេះអាចត្រូវរំលាយទៅវិញប្រសិនបើ មានភស្តុតាងផ្ទុយ ដោយបញ្ជាក់ថាការតបតនោះមិនមែនជាការការពារខ្លួនទៅវិញ។[28]

### ៤.៥.ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងស្ថានភាពមួយ ដែលចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ បើសិនជាការប្រព្រឹត្តិនោះ ស្ថិតនៅក្នុងកាលៈទេសៈមួយដែលត្រូវការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ការការពារដើម្បីប្រឆាំងទៅនឹងស្ថានភាពដែលកំពុងគ្រោះថ្នាក់ ឬស្ថានភាពគ្រោះថ្នាក់ដែលនឹងកើតឡើងនាពេលខាងមុខ។ ចំពោះការការពារនោះដែរត្រូវតែ គ្មានវិសមាមាត្ររវាង មធ្យោបាយការពារនិងទំហំនៃគ្រោះថ្នាក់នោះទេ។[29] មូលហេតុស្ថានភាពចំបាច់ស្រដៀងនឹងការការពារស្របច្បាប់ដែរ គ្រាន់តែមិនមានអំពើឈ្លានពានស្ថិតក្នុងស្ថានភាពនេះទេ គឺអ្នកប្រព្រឹត្តប្រឈមនឹងស្ថានភាពធម្មជាតិ ឬហេតុការណ៍ណាមួយ។

### ៤.៦.អានុភាពនៃកម្លាំង ឬការបង្ខំ

ការប្រព្រឹត្តិបទល្មើស ក្រោមអានុភាពនៃកម្លាំងណាមួយ ឬក្រោមការបង្ខំពីអ្នកដទៃ ដោយការបង្ខំមិនអាចមើលដឹងមុន និងមិនអាចជៀសផុតបាន។[30] ដូចជាក្នុងករណីមានគេចាប់ប្អូនគំរាមនឹងកំបិត ដើម្បីបង្ខំឱ្យបងទៅឆបោកអ្នកដទៃ ទង្វើនេះជាបទល្មើសព្រហ្មទណ្ឌ តែមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ ទង្វើល្មើសនេះទេ ដោយសារតែអ្នកប្រព្រឹត្ត ស្ថិតក្នុងស្ថានភាពនៃការគំរាមគំហែងពីអ្នកដទៃដើម្បីឱ្យខ្លួនប្រព្រឹត្តបទល្មើសដោយបង្ខំ។

### ៤.៧.អ្នកប្រព្រឹត្តជាអនីតិជន

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ។[31]

---

[28] មាត្រា៣៤ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[29] មាត្រា៣៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[30] មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[31] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ជនល្មើសមានអាយុចាប់ពី ១៨(ដប់ប្រាំបី)ឆ្នាំ ឡើងទៅ ទើបតុលាការអាចផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌបាន ដោយទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ក៏ប៉ុន្តែមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ បានចែងថាអនីតិជនមានអាយុចន្លោះពី ១៤(ដប់បួន)ឆ្នាំ ទៅដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ តុលាការអាចវិនិច្ឆ័យទោសទៅតាមកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន។ ក្នុងករណីដែលចៅក្រមសម្រេចចោទប្រកាន់ក្រមព្រហ្មទណ្ឌ មាត្រា១៦០ បានកំណត់ថាទោសដែលត្រូវចោទប្រកាន់ទៅលើបទល្មើសនោះត្រូវកាត់បន្ថយពាក់កណ្តាលពីទោសធម្មតា ឬអប្បបរមានៃទោសនោះលើសពី ១(មួយ)ថ្ងៃ។ បើអប្បបរមានៃទោសនោះត្រូវដាក់ពន្ធនាគារអស់មួយជីវិត ត្រូវកាត់បន្ថយមកត្រឹម ២០(ម្ភៃ)ឆ្នាំ។

បើយោងទៅតាមគោលការណ៍ អនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ឡើងទៅត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[32] ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន និងប្រគល់អនីតិជនឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីដែលអនីតិជននោះមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ គិតត្រឹមថ្ងៃសង្ស័យចូលរួមប្រព្រឹត្តបទល្មើស។[33] ទោះបីជាព្រះរាជអាជ្ញារកឃើញពីអត្ថិភាពនៃបទល្មើសនោះក៏ដោយ។

### ៥. មូលហេតុផ្សេងទៀតនៃការរលត់នៃបណ្តឹងអាជ្ញា

ការតម្កល់រឿងទុកឥតចាត់ការអាចធ្វើឡើងបានដោយផ្អែកទៅលើ មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញាបានដែរ មូលហេតុនេះផងដែរត្រូវបានដោះស្រាយតាមបែបផ្សេងទៀត។ លក្ខខណ្ឌដែលអាចឱ្យបណ្តឹងអាជ្ញាអាចផុតរលត់បាន កាលណាច្បាប់ដោយឡែកបានចែងជាក់លាក់ ដោយមានការសម្របសម្រួលជាមួយរដ្ឋ ដោយការដកពាក្យប្តឹងនៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។[34]

#### ៥.១.ការសម្របសម្រួលជាមួយរដ្ឋ

នៅពេលដែលជនល្មើសដឹងពីកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ហើយអំពើល្មើសនោះមិនបានផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរ ដល់សណ្តាប់ធ្នាប់សង្គមសាធារណៈ ឬប៉ះពាល់ដល់ផលប្រយោជន៍របស់រដ្ឋ។ ជននោះអាចធ្វើការសម្របសម្រួលជាមួយរដ្ឋបានដោយមាន កិច្ចសន្យាជាលាយលក្ខណ៍អក្សរដើម្បីជាសំអាងហេតុពីកំហុសរបស់ខ្លួន និងសម្រាប់ជាការសន្យាចំពោះរដ្ឋ ដើម្បីទទួលបានការលើកលែងទោសពីរដ្ឋ ដោយបំពេញនូវលក្ខខណ្ឌដែលរដ្ឋបានដាក់ឱ្យ។ ជាពិសេសករណីបទល្មើសពន្ធគយ។

[32] មាត្រា១៦០ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[33] មាត្រា២៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[34] មាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដូចជាករណី ក្រុមហ៊ុន **ក** បាននាំទំនិញគ្រឿងសំអាងថែរក្សាសម្រស់ពីបរទេស តែបានលួចបន្លែមគេចពន្ធសម្លៀកបំពាក់ នៅពេលដែលរដ្ឋរកឃើញថា មានទំនិញផ្សេងទៀតដែល ក្រុមហ៊ុន **ក** បាននាំចូលខុសច្បាប់ នោះរដ្ឋតម្រូវឱ្យ ក្រុមហ៊ុន **ក** បង់ពន្ធជូនរដ្ឋនូវទំនិញដែលមិនទាន់បានបង់ ដើម្បីឱ្យរលត់នូវបណ្តឹងអាជ្ញា។

**៥.២.ការដកពាក្យបណ្តឹងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ**

តាមគោលការណ៍បទល្មើសព្រហ្មទណ្ឌ ទោះបីជាជនរងគ្រោះដកពាក្យបណ្តឹង ក៏មិនអាចរំលត់បណ្តឹងអាជ្ញាបាននោះដែរ។ ទោះបីជាជនរងគ្រោះព្រមដកពាក្យបណ្តឹង ឬព្រមទទួលសំណងនៃការខូចខាតក៏ដោយ ព្រះរាជអាជ្ញានៅតែមានសិទ្ធិសម្រេចអាចចោទប្រកាន់ទៅលើបទល្មើសនោះបានដដែល។ ប៉ុន្តែមានបទល្មើសមួយចំនួនដែលរឿងក្តីព្រហ្មទណ្ឌ ឬបណ្តឹងអាជ្ញា មិនអាចដំណើរការបាន បើសិនជាជនរងគ្រោះមិនបានដាក់ពាក្យបណ្តឹង ឬដកពាក្យបណ្តឹងទៅវិញ។ បទល្មើសមួយចំនួន ដែលត្រូវបានច្បាប់កំណត់ថា បើជនរងគ្រោះបានដកពាក្យបណ្តឹង នោះបណ្តឹងអាជ្ញានឹងត្រូវរលត់។ យោងទៅតាម ច្បាប់នៃឯកពន្ធភាព (ផិតក្បត់) បុរស ឬស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍ទៅតាមច្បាប់ពីមុនមិនទាន់រលាយ ហើយលួចទៅមានទំនាក់ទំនងជាមួយបុរស ឬស្ត្រី ដទៃទៀតចាត់ទុកថាជាបទផិត។[35] ក្នុងករណីនេះផងដែរព្រះរាជអាជ្ញា អាចសម្រេចមិនធ្វើបណ្តឹងអាជ្ញាបាន ប្រសិនបើសហព័ទ្ធបានដាក់បណ្តឹងស្នើសុំដើម្បីកុំឱ្យធ្វើការចោទប្រកាន់ទៅលើសហព័ទ្ធម្ខាងទៀត។[36] រួមទាំងការជេរប្រមាថ ឬបរិហារកេរ្តិ៍ មិនអាចចោទប្រកាន់បានទេ បើសិនជាគ្មានការដាក់ពាក្យបណ្តឹង ពីសំណាក់ជនរងគ្រោះ ប្រសិនបើពាក្យបណ្តឹងដែលបានដាក់ហើយ ត្រូវដកទៅវិញដោយជនរងគ្រោះនោះបណ្តឹងអាជ្ញានឹងត្រូវរលត់ដូចគ្នា។

ចំពោះករណីហិង្សាក្នុងគ្រួសារវិញ ក៏ដូចគ្នាដែរ រាល់ការដាក់ពាក្យបណ្តឹង ឬដកពាក្យបណ្តឹងគឺអាស្រ័យទៅលើជនរងគ្រោះជានីតិជន ចំពោះតែអំពើដែលមានលក្ខណៈជា បទលហុ ឬបទមជ្ឈិមស្រាលប៉ុណ្ណោះ។[37] ដោយឡែកបទឧក្រិដ្ឋ ឬបទមជ្ឈិមធ្ងន់ធ្ងរ ព្រះរាជអាជ្ញានៅតែអាចធ្វើការចោទប្រកាន់បាន ទោះមិនមានបណ្តឹងក៏ដោយ។[38] ប៉ុន្តែអំពើហិង្សាក្នុងគ្រួសារ អាចសម្របសម្រួលឱ្យដកពាក្យបណ្តឹងបាន ចំពោះតែករណីដែលនគរបាលយុត្តិធម៌ បានទទួលបណ្តឹងជាលើកទីមួយប៉ុណ្ណោះ ប្រសិនបើមានករណីដដែលនេះទទួលបណ្តឹងជាលើកទីពីរ មិនមានការលើកលែងសម្របសម្រួលទៀតនោះទេ។ អំពើហិង្សាក្នុងគ្រួសារ មិនសំដៅតែអំពើហិង្សា

[35] មាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

[36] មាត្រា៨ ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦

[37] មាត្រា៣៦ នៃច្បាប់ស្តីអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

[38] មាត្រា១៩ នៃច្បាប់ស្តីអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

ទៅលើសហព័ទ្ធតែមួយនោះទេ រួមទាំងកូនក្នុងបន្ទុក ជនទាំងឡាយដែល រស់នៅក្រោមដំបូលផ្ទះតែមួយ និងនៅក្នុងបន្ទុកគ្រួសារផងដែរ។[39]

### ៥.៣.ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល

តាមគោលការណ៍បទល្មើសព្រហ្មទណ្ឌ មិនអាចទទួលសំណងហើយ រួចផុតពីការទទួលខុសត្រូវបាននោះទេ។ ប៉ុន្តែមានបទល្មើសមួយចំនួនមិនអាចធ្វើការចោទប្រកាន់បានទេ ដោយគ្រាន់តែទទួលការសម្របសម្រួលដោយការពិន័យ។ ដូចជាបទល្មើសចរាចរណ៍ផ្លូវគោក ជនដែលបានប្រព្រឹត្តល្មើសច្បាប់ចរាចរណ៍ផ្លូវគោក ត្រូវពិន័យជាប្រាក់ ដើម្បីឱ្យបណ្តឹងអាជ្ញារលត់។[40]

តំណាងអយ្យការមិនធ្វើការចោទប្រកាន់ទៅលើបទល្មើសនេះទេ ទោះបីជាអំពើនោះជាអំពើល្មើសក៏ដោយ តំណាងអយ្យការមានសិទ្ធិក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ផ្អែកលើការពិចារណាទៅលើសំអាងច្បាប់ និងសំអាងហេតុ។

បទល្មើសដែលបង្កឡើងដោយគ្រោះថ្នាក់ចរាចរណ៍ ក៏ជាបទល្មើសព្រហ្មទណ្ឌដែរ ប្រសិនបើបទល្មើសនោះបង្កនូវព្យសនកម្មធ្ងន់ធ្ងរ បណ្តាលឱ្យបាត់បង់ជីវិតជាដើម មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងណាមួយទុកឥតចាត់ការបានទេ ទោះជាមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬមានការដកពាក្យបណ្តឹងក៏ដោយ[41] ក៏តំណាងអយ្យការមានសិទ្ធិទៅលើរឿងក្តីព្រហ្មទណ្ឌដែរ។ ប៉ុន្តែប្រសិនបើគ្រោះថ្នាក់នោះគ្រាន់តែបណ្តាលឱ្យ ខូចខាតទ្រព្យសម្បត្តិអ្នកដទៃទេ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកអាចសម្រុះសម្រួលដោយការសងសំណងនៃខូចខាតបាន[42] ឬភាគីទាំងសងខាងអាចសម្រុះសម្រួលគ្នាបានដោយមិនបាច់មានការអន្តរាគមន៍ ពីមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកក៏បាន។[43]

នៅក្នុងករណីបទល្មើសព្រៃឈើ មានបទល្មើសមួយចំនួនក៏ស្ថិតនៅក្នុងបទល្មើសព្រហ្មទណ្ឌដូចគ្នាតែមានចរិតលក្ខណៈពិសេស។ តែមានបទល្មើសមួយចំនួនទៀត រដ្ឋបាលព្រៃឈើមានសិទ្ធិពិន័យជាអន្តការណ៍ក្នុងករណីដែលជនល្មើស ព្រមសារភាពនូវទោសកំហុសរបស់ខ្លួន និងព្រមបង់ប្រាក់ពិន័យទៅតាមទោសបញ្ញត្តិ។[44]

---

[39] មាត្រា២ នៃច្បាប់ស្តីអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

[40] មាត្រា៨៧ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

[41] មាត្រា៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[42] មាត្រា៦៥ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

[43] មាត្រា៣៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

[44] មាត្រា៩១ នៃច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២

## ផ្នែកទី៣៖ សមត្ថកិច្ចក្នុងការតម្កល់រឿងទុកឥតចាត់ការរបស់ស្ថាប័នអយ្យការ

### កថាខណ្ឌទី១៖ ស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលស្ថិតនៅក្រោមអំណាចរបស់អង្គការនីតិប្រតិបត្តិ អមតុលាការក្នុងការជម្រះក្តី។ ជាអ្នកតំណាងឱ្យសង្គម ដើម្បីផលប្រយោជន៍ទូទៅ ដែលជាម្ចាស់នៃបណ្តឹងអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ។ ស្ថាប័នអយ្យការមានតួនាទី ក្នុងការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ និងធ្វើការសន្និដ្ឋានឱ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[45] ស្ថាប័នអយ្យការជាអ្នកធានារ៉ាប់រងនូវការអនុវត្តន៍ សេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងធានាលើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។[46]

ស្ថាប័នអយ្យការ មានឋានានុក្រម តាមការប្រើប្រាស់អំណាចអធិបញ្ញា។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអម សាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋាន តាមដែលរដ្ឋមន្ត្រីបានយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់ អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការ នូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។[47] ដោយសារស្ថាប័នអយ្យការ ជាស្ថាប័នមានឋានានុក្រម ដូចនេះហើយបានជាក្រមនីតិវិធីព្រហ្មទណ្ឌចែងថា នៅក្នុងករណីដែលមាន បទល្មើសធ្ងន់ធ្ងរ ព្រះរាជាអាជ្ញារាយការណ៍ជូន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[48]

ដូចនេះស្ថាប័នអយ្យការមានសិទ្ធិអំណាចសើរើសំណុំរឿងឡើងវិញ ដរាបណាអាជ្ញាយុកាលនៃបណ្តឹងមិនទាន់រលត់។

#### ១. រចនាសម្ព័ន្ធស្ថាប័នអយ្យការ

ស្ថាប័នអយ្យការ មាន ៣ (បី) ថ្នាក់ ដែលថ្នាក់នីមួយៗស្ថិតទៅតាមតុលាការទាំងបីដូចគ្នា។ អយ្យការអមសាលាដំបូងខេត្ត-រាជធានី ដែលតំណាងដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។ មហាអយ្យការអមសាលាឧទ្ធរណ៍ តំណាងដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញារង អមសាលាឧទ្ធរណ៍ និង

[45] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[46] មាត្រា២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[47] មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[48] មាត្រា៤០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ មហាអយ្យការអមតុលាការកំពូល តំណាងដោយ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល និងព្រះរាជអាជ្ញាអមតុលាការកំពូល។[49]

### ១.១.អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ជាតំណាងស្ថាប័នអយ្យអមសាលាដំបូងខេត្ត-រាជធានី។[50] ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្ត មានសិទ្ធិអំណាចក្នុងការដឹកនាំ និងសម្របសម្រួលដល់សកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីខ្លួន។ អាចធ្វើអធិការកិច្ច បានគ្រប់ពេលនៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចចូលរួម ក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យវិធានការឃាត់ខ្លួន ការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។[51] ព្រះរាជអាជ្ញារង ស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ក្នុងការប្រើប្រាស់អំណាចទាំងអស់ដែល ព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស។[52]

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការបាន ដោយផ្អែកលើ សេចក្តីសម្រេចដែលមានសំអាងច្បាប់ និងសំអាងហេតុ សេចក្តីសម្រេចនៃការតម្កល់រឿងទុកឥតចាត់ការ មិនមានអាជ្ញាអស់ជំនុំទេ គឺជាសមិនផុតពីការប្តឹងតវ៉ាឡើយ។ ដូចនេះស្ថាប័នអយ្យការ ដែលមានតំណាងអយ្យការជា ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារងមានសិទ្ធិអំណាចសើរើសំណុំរឿងឡើងវិញ ដរាបណាអាជ្ញាយុកាលនៃបណ្តឹងមិនទាន់រលត់ បន្ទាប់ពីទទួលបណ្តឹងតវ៉ា ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ដែលជាតំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ត្រូវបញ្ជូនសំណុំរឿងទៅកាន់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

### ១.២.មហាអយ្យការអមសាលាឧទ្ធរណ៍

តំណាងរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ គឺអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍។ ហើយសាលាឧទ្ធរណ៍ជាសាលាជម្រះក្តីថ្នាក់ទីពីរ រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍ថ្នាក់តំបន់។[53] បច្ចុប្បន្ននេះសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ សាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍

[49] មាត្រា២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[50] មាត្រា៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[51] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[52] មាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[53] មាត្រា៣៥ នៃច្បាប់ស្តីអំពីការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

បាត់ដំបង សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ។ ដោយផ្អែកតាម ព្រះរាជក្រឹត្យលេខ នស/រកត/១៣០០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ដំណើរការសាលាដំបូងភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។ ព្រះរាជក្រឹត្យលេខ នស/រកត/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដំណើរការសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ ព្រះរាជក្រឹត្យលេខ នស/រកត/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង។ ព្រះរាជក្រឹត្យលេខ នស/រកត/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ។ ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់។

– សាលាឧទ្ធរណ៍ភ្នំពេញ មានសមត្ថកិច្ចជំនុំជម្រះក្តីដែលនៅក្នុង សមត្ថកិច្ចដែនដីគ្រប់ដណ្តប់លើរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ព្រមទាំងរឿងក្តីដែលមិនស្ថិតក្រោមសមត្ថកិច្ចឧទ្ធរណ៍តំបន់ លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចឱ្យតុលាការផ្សេងទៀត។[54]

– សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ ត្រូវទទួលបន្ទុកដោះស្រាយបណ្តឹងសាលាឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនានា របស់សាលាដំបូងកំពង់ចាម និងអយ្យការអមសាលាដំបូងកំពង់ចាម សាលាដំបូងកំពង់ធំ និងអយ្យការអមសាលាដំបូងកំពង់ធំ សាលាដំបូងព្រះវិហារ និងអយ្យការអមសាលាដំបូងព្រះវិហារ សាលាដំបូងរតនគិរី និងអយ្យការអមសាលាដំបូងរតនគិរី សាលាដំបូងមណ្ឌលគិរី និងអយ្យការអមសាលាដំបូងមណ្ឌលគិរី សាលាដំបូងស្វាយរៀង និងអយ្យការអមសាលាដំបូងស្វាយរៀង និងចុងក្រោយសាលាដំបូងត្បូងឃ្មុំ និងអយ្យការអមសាលាដំបូងត្បូងឃ្មុំ ឬករណីសំណុំរឿងដែលតុលាការកំពូលបង្វិលមកវិញ។[55]

– សាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង មានទីតាំងនៅខេត្តបាត់ដំបូង និងមានដែនសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីដែលស្ថិតក្នុងដែនសមត្ថកិច្ចដែនដីគ្របដណ្តប់លើខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ឧត្តរមានជ័យ និងសៀមរាប លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចឱ្យតុលាការផ្សេងទៀត។

[54] មាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

[55] ព្រះរាជក្រឹត្យលេខ នស/រកត/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩

– សាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ មានទីតាំងនៅខេត្តព្រះសីហនុ និងមានសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្តប់លើខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត ខេត្តកែប លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចឱ្យតុលាការផ្សេងទៀត។

បើយោងទៅតាមមាត្រា៣៤ និងមាត្រា៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានតួនាទីក្នុងការឃ្លាំមើលការអនុវត្តច្បាប់ ត្រួតពិនិត្យនៅក្នុងសមត្ថកិច្ចដែនដី នៃសាលាឧទ្ធរណ៍របស់ខ្លួនដូចជាមន្ត្រីនគរបាលយុត្តិធម៌ជាដើម អគ្គព្រះរាជអាជ្ញាអាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលយុត្តិធម៌ ឱ្យមកពិភាក្សាអំពីបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្តិទៅរបស់អង្គភាពនេះ។ អគ្គព្រះរាជអាជ្ញាមានសិទ្ធិប្រគល់ភារកិច្ចដល់មន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឱ្យបំពេញភារកិច្ចទាំងឡាយ ដែលខ្លួនយល់ថាមានប្រយោជន៍ដល់ការគ្រប់គ្រង ឬដំណើរការល្អនៃនគរបាលយុត្តិធម៌ និងធ្វើអធិការកិច្ចគ្រប់ពេល ទៅលើអង្គភាពនគរបាលយុត្តិធម៌។

សាលាឧទ្ធរណ៍ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងជំទាស់ កើតទុក្ខមិនសុខចិត្តលើសេចក្តីសម្រេចរបស់តុលាការជាន់ទាបដែលជាសាលាដំបូងរាជធានី-ខេត្ត។ មហាអយ្យការអមសាលាឧទ្ធរណ៍ អាចទទួលសំណុំរឿងក្តីព្រហ្មទណ្ឌណាមួយ មកចាត់ការបានលុះត្រាតែ អយ្យការអមសាលាដំបូងខេត្ត-រាជធានីសម្រេចតម្កល់សំណុំរឿងទុកឥតចាត់ការ បើមានបណ្តឹងឧទ្ធរណ៍លើដីកា សម្រេចតម្កល់រឿងទុកឥតចាត់ការនោះទើប អយ្យការអមសាលាដំបូងខេត្ត-រាជធានី ធ្វើការបញ្ជូនមកមហាអយ្យការអមសាលាឧទ្ធរណ៍ពិនិត្យចាត់ការបន្ត។

### ១.៣.មហាអយ្យការអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃមហាអយ្យការអមតុលាការកំពូល[56] ដែលតុលាការកំពូលមានតែមួយគត់នៅរាជធានីភ្នំពេញ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់ នៅពេលដែលមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដែលដាក់ទៅតុលាការកំពូលដើម្បីពិនិត្យ[57] និងចូលរួមដឹកនាំ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលផងដែរ។ បើយោងទៅតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា៧០ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលទទួលសេចក្តីសន្និដ្ឋានពី

---

[56] មាត្រា៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[57] មាត្រា៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីពិនិត្យមុនពេលសាវនាការ។ នៅពេលដែលអគ្គព្រះរាជអាជ្ញាមិនយល់ព្រមលើ សេចក្តីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញា ហើយមហាអយ្យការអមតុលាការកំពូលមិនយល់ព្រមធ្វើតាម។ អគ្គព្រះរាជអាជ្ញាអាចមានសិទ្ធិក្នុងការ ចាត់តាំងឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ឬចាត់តាំងខ្លួនឯងផ្ទាល់ធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ។

អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ជាអ្នកធ្វើសេចក្តីសន្និដ្ឋានទៅ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និងធ្វើការកត់សម្គាល់ដោយសេរីតាមសតិសម្បជញ្ញៈរបស់ខ្លួនដោយគ្មានការចោទប្រកាន់ខាងវិន័យណាមួយ នៅពេលដែលធ្វើជាតំណាងមហាអយ្យការ ដោយមានការចាត់តាំងដោយអគ្គព្រះរាជអាជ្ញាខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលត្រូវទទួលការពិនិត្យពីអគ្គព្រះរាជអាជ្ញាដោយផ្ទាល់។

តុលាការកំពូល គឺជាសាលាជម្រះក្តីជាន់ខ្ពស់ និងចុងក្រោយបង្អស់ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ាមានលក្ខណៈស្ថាពរ ។

**២. តួនាទីរបស់តំណាងអយ្យការ**

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ជាតំណាងរបស់ តំណាងអយ្យការក្នុងការតម្កល់រឿងទុកឥតចាត់ការ។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ទទួលបានសិទ្ធិអំណាចដោយផ្អែកទៅលើ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលជាអំណាចឆន្ទានុសិទ្ធិ របស់តំណាងអយ្យការក្នុងការតម្កល់រឿងទុកឥតចាត់ការ។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង មានតួនាទី ភារកិច្ច សមត្ថកិច្ច និងសិទ្ធិអំណាចផ្សេងៗទៀតផងដែរ។

នៅក្នុងដំណើរការ នីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាមានតួនាទីចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងអនុវត្តច្បាប់នៅចំពោះមុខ យុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[58]

ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តាមរយៈ ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះក្តីផ្ទាល់ និងតាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាម។[59] ដើម្បីជាជម្រើសថាអាចជ្រើសយកជម្រើសនៃការចោទប្រកាន់ ឬដោយធ្វើការតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាគិតពិចារណាទៅលើ លក្ខខណ្ឌនៃបទល្មើស ថាគួរតែចោទប្រកាន់ ឬមិនចោទប្រកាន់។ តែមិនអាចធ្វើការចោទប្រកាន់បានឡើយប្រសិនបើមិនទាន់មានការ ស៊ើបអង្កេត ឬស្រាវជ្រាវពីអង្គហេតុនៃបទល្មើសនោះ។

ដូចបានរៀបរាប់នៅក្នុងចំណុច អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ពីតួនាទីខ្លះរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដោយតំណាងអយ្យការក្នុងការតម្កល់រឿងទុកឥតចាត់ការ គឺដូចគ្នានឹងអយ្យការអម

[58] មាត្រា៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[59] មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សាលាដំបូងរាជធានី-ខេត្ត។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ធ្វើការជាតំណាងអយ្យការទៅតាមសាលាដំបូងដែលខ្លួនបំពេញការងារ។

### ២.១. គោលការណ៍របស់តំណាងអយ្យការ

តំណាងអយ្យការ មានសិទ្ធិក្នុងការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ សុំឱ្យអនុវត្តច្បាប់ ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ធានាឱ្យមានការអនុវត្តន៍សេចក្ដីសម្រេច រួមទាំងចេញដីកាឱ្យចាប់ខ្លួនផងដែរ។ ដោយតំណាងអយ្យការមានគោលការណ៍សំខាន់ៗដូចជា៖[60]

– គោលការណ៍ឯកភាព៖ អង្គការអយ្យការ គឺជាអង្គឯកភាព ដែលមានព្រះរាជអាជ្ញាទាំងអស់ស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យ។ ដោយមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជានាយឋានានុក្រម នៃអង្គការអយ្យការ អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអយ្យការគ្រប់ជាន់ថ្នាក់។

– គោលការណ៍អវិភាគ៖ អង្គការអយ្យការ គឺជាអង្គអវិភាគ ដែលព្រះរាជអាជ្ញាច្រើនរូប មានមុខងារដូចគ្នាក្នុងការបំពេញកាតព្វកិច្ច ហើយអាចជំនួសគ្នាទៅវិញទៅមក ដោយអាចបន្តការងារពីគ្នានៅក្នុងរឿងក្ដីតែមួយនៅក្នុងអង្គការអយ្យការ សាលាជម្រះក្ដីណាមួយ។

– គោលការណ៍ឯករាជ្យ៖ អង្គការអយ្យការ គឺជាអង្គឯករាជ្យក្នុងការជម្រះក្ដី មិនមានសិទ្ធិអំណាចត្រួតពិនិត្យកិច្ចការ របស់ព្រះរាជអាជ្ញាទេ ដោយសារតែព្រះរាជអាជ្ញា មិនស្ថិតនៅក្រោមអំណាចរបស់សាលាជម្រះក្ដីដែលខ្លួនអមនោះទេ ទោះបីជាព្រះរាជអាជ្ញាមានកំហុសក្នុងការបំពេញមុខងាររបស់ខ្លួនក៏ដោយ។ សាលាជម្រះក្ដីមិនអាចចុះក្នុងសេចក្ដីសម្រេច ដើម្បីធ្វើការស្ដីបន្ទោសចំពោះ ព្រះរាជអាជ្ញាបានឡើយទាំងក្នុងរឿងក្ដីព្រហ្មទណ្ឌ និងក្នុងរឿងក្ដីផ្សេងទៀតដែរ។ ប៉ុន្តែសាលាជម្រះក្ដី អាចលើកសំណើរ ទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញាពីកំហុសរបស់ព្រះរាជអាជ្ញាបាន។

[60] មាត្រា៧៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈ នៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

# ជំពូកទី២៖
# នីតិវិធី និងអានុភាពនៃការតម្កល់
# រឿងទុកឥតចាត់ការ

# ជំពូកទី២៖
# នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

## ផ្នែកទី១៖ នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

### កថាខណ្ឌទី១៖ ការទទួលពាក្យបណ្តឹង

យោងទៅតាមមាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បុគ្គលគ្រប់រូបដែលប្រកាសខ្លួនជាជនរងគ្រោះ នៅក្នុងបទល្មើស ជនទាំងនោះអាចដាក់ពាក្យប្តឹងបាន។ ដោយឡែក បណ្តឹងសាមញ្ញនេះ គឺគ្មានអានុភាព នាំឱ្យមានការចោទប្រកាន់ណាមួយជាបទព្រហ្មទណ្ឌឡើយ។ ការដាក់ពាក្យបណ្តឹងនេះ គឺដើម្បីប្រកាសប្រាប់ ស្ថាប័នមានសមត្ថកិច្ចឱ្យផ្តើមធ្វើចំណាត់ការតាមច្បាប់។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបានពាក្យបណ្តឹងនេះហើយ ត្រូវតែធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនេះ។ បន្ទាប់ពីធ្វើកំណត់ហេតុបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ ចាប់ផ្តើមធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬសុំការអនុញ្ញាតពី ព្រះរាជអាជ្ញាដើម្បី បើកការស៊ើបសួរ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែបញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះ ទៅឱ្យព្រះរាជអាជ្ញាដើម្បីធ្វើចំណាត់ការបន្ត។ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌទុកឥតចាត់ការបានឡើយ បើទោះបីជាមានការសម្របសម្រួលរវាងជនល្មើស និងជនរងគ្រោះក្តី។[61]

### កថាខណ្ឌទី២៖ ការស៊ើបអង្កេតបឋម ឬស្រាវជ្រាវបន្ថែម

នៅពេលដែលទទួលបាននូវពាក្យប្តឹងសុំតម្កល់រឿងទុកឥតចាត់ការ ឬពាក្យបរិហារដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ បុគ្គលដែលមានអំណាចក្នុងការ ចោទប្រកាន់ ឬមិនចោទប្រកាន់ ពោលគឺតំណាងអយ្យការ ត្រូវត្រួតពិនិត្យលើពាក្យប្តឹងនោះ ដើម្បីឱ្យប្រាកដថារឿងក្តីនោះមានលក្ខណៈបែបណា។ ប៉ុន្តែបើទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចតម្កល់រឿងទុកឥតការនេះ តំណាងអយ្យការដែលរួមមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ត្រូវតែបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម មុននឹងចេញសេចក្តីសម្រេចតម្កល់ ឬមិនតម្កល់។[62] ការស៊ើបអង្កេតបឋម គឺជាការស៊ើបអង្កេតដែលធ្វើឡើង មុនដំណាក់កាលនៃការជំនុំជម្រះ ដោយមន្ត្រីនគរបាលយុត្តិធម៌។[63] នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌បានដឹងពីអំពើ ដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌នោះអាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ប្រសិនបើការស៊ើបអង្កេតទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលត្រូវ

[61] មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[62] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[63] មាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

រាយការណ៍ជូនភ្លាមៗ ទៅព្រះរាជអាជ្ញា។[64] ប្រសិនមន្ត្រីនគរបាលយុត្តិធម៌កំពុងតែធ្វើការស៊ើបអង្កេតបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួល ការយល់ព្រមបឋម ជាលាយលក្ខណ៍អក្សរពីអ្នកកាន់កាប់ទីកន្លែងនោះជាមុនសិន។ ក្នុងករណីដែលមាន ការយល់ព្រមឱ្យធ្វើការឆែកឆេរ ឬអ្នកកាន់កាប់ទីកន្លែងអវត្តមាន នោះនគរបាលយុត្តិធម៌ត្រូវទទួលការ អនុញ្ញាត ពីប្រធានសាលាដំបូងដែលពាក់ព័ន្ធ តាមការសុំរបស់ព្រះរាជអាជ្ញាមុននឹងធ្វើការឆែកឆេរ។[65]

**កថាខណ្ឌទី៣៖ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ**

បន្ទាប់ពីបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមត្រូវបានបញ្ចប់សព្វគ្រប់ហើយនោះ។ បើតំណាងអយ្យការយល់ឃើញថា រឿងក្តីត្រូវតែតម្កល់ទុកឥតចាត់ការ ចំពោះពាក្យប្តឹង ឬពាក្យបរិហារ តំណាងអយ្យការនឹងចេញនូវដីកាមួយដែលមានឈ្មោះថា "**ដីកាតម្កល់រឿងទុកឥតចាត់ការ**"។

**កថាខណ្ឌទី៤៖ ការជូនដំណឹងទៅភាគីដើមបណ្តឹង**

ក្រោយពេលដែលតំណាងអយ្យការចេញដីកា សម្រេចតម្កល់រឿងទុកឥតចាត់ការ ជំហានបន្ទាប់គឺត្រូវជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុង រយៈពេលយ៉ាងខ្លីបំផុត បើទោះបីជាយូរយ៉ាងណាក៏ដោយ ក៏មិនត្រូវឱ្យលើស ពីរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីក្នុងបទប្បញ្ញត្តិ មាត្រា៥០ (បញ្ជីនៃពាក្យប្តឹង)។[66]

ការជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ គឺជារឿងដែលចាំបាច់បំផុតរបស់ព្រះរាជអាជ្ញា ក្នុងការបំពេញ ដើម្បីឱ្យភាគីដើមបណ្តឹងដែលមិនសុខចិត្តនឹងសេចក្តីសម្រេច ធ្វើការប្តឹងតវ៉ាទៅអគ្គព្រះរាជអជ្ញាអមសាលាឧទ្ធរណ៍ ពីអគ្គព្រះរាជអាជ្ញា ជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។ ការតម្កល់រឿងទុកឥតចាត់ការ គឺជានីតិវិធីមួយដែលមាន លក្ខណៈស្លូតបូតរបស់អយ្យការក្នុងការមិនចោទប្រកាន់ ជនល្មើសពីបទព្រហ្មទណ្ឌ។ ការសម្រេចមិនចោទប្រកាន់អាចជាការថ្លឹងថ្លែង ប្រកបដោយការត្រិះរិះពិចារណា ឆ្លងកាត់ការស្រាវជ្រាវស៊ើបអង្កេតយ៉ាងល្អិតល្អន់ផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចតម្កល់រឿងទុកឥតចាត់ការខ្លះក៏មានភាពខុសឆ្គងមួយចំនួនដែរ។ ហេតុដូច្នេះហើយ ដើម្បីធានាថាកាតម្កល់រឿងទុកឥតការ ប្រព្រឹត្តទៅដោយយុត្តិធម៌ ត្រឹមត្រូវតាមផ្លូវច្បាប់ ក្រមនីតិវិធីព្រហ្មទណ្ឌមានចែងនៅ នីតិវិធីដោះស្រាយផ្សេងៗ លើចំណាត់ការប្រភេទបែបនេះ។ ដើម្បីបញ្ចៀសនៅបញ្ហាអយុត្តិធម៌ កើតមានឡើងនៅក្នុងសង្គម ក្នុងការការពារនូវផលប្រយោជន៍របស់ជនរងគ្រោះ ក៏ដូចជាផលប្រយោជន៍របស់អ្នកពាក់ព័ន្ធទាំងឡាយផងដែរ មូលហេតុទាំងនេះក៏មិនអាចរារាំងការចោទប្រកាន់ឡើងវិញបាននោះទេ។

---

[64] មាត្រា ៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[65] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[66] មាត្រា ៤១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

## ផ្នែកទី២៖ អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### កថាខណ្ឌទី១៖ អានុភាពគ្មានអាជ្ញាអស់ជំនុំទៅលើបណ្តឹងអាជ្ញា

ចំពោះការតម្កល់រឿងទុកឥតចាត់ការនេះ គឺពុំបង្កើតអានុភាពអាជ្ញាអស់ជំនុំនោះទេ។[67] តាមគោលការណ៍អាជ្ញាអស់ជំនុំ[68] ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរ ហើយជននោះមិនអាចត្រូវចោទប្រកាន់ម្តងទៀតទេ ចំពោះអំពើដែលបានប្រព្រឹត្តដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីមួយទៀតក៏ដោយ។ ដោយឡែកចំពោះការតម្កល់រឿងទុកឥតចាត់ការ ភាគីនៃជនរងគ្រោះនៅតែអាចមានសិទ្ធិ ប្តឹងជំទាស់ទៅកាន់ស្ថាប័នដែលទទួលបន្ទុកដោះស្រាយរឿងនេះ។

### កថាខណ្ឌទី២៖ ផ្តើមគិតចិរវេលាអាជ្ញាយុកាលនៃបទល្មើសជាថ្មី

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិ អំពីកិច្ចដែលត្រូវបានកាត់ផ្តាច់រយៈពេល នៃអាជ្ញាយុកាលនៃបទល្មើសបាន។ ពោលគឺនៅគ្រប់កិច្ចនៃការចោទប្រកាន់របស់អយ្យការ ឬកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរ។ នៅពេលដែលបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល។ ដូចជាករណី៖ បទល្មើសលួច បានប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០២។ តំណាងអយ្យការបានចេញដីកាតម្កល់រឿងទុកឥតចាត់ការ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០។ ដូច្នេះចិរវេលានៃបទល្មើស លួច ខាងលើត្រូវគិតរាប់សារជាថ្មី ដោយសារតែមានការកាត់ផ្តាច់ នៃអាជ្ញាយុកាលដោយកិច្ចចោទប្រកាន់របស់អយ្យការ។

### កថាខណ្ឌទី៣៖ ការរួចផុតពីការចោទប្រកាន់

ដីកាតម្កល់រឿងទុកឥតចាត់ការ អាចមានអានុភាពដល់ជនសង្ស័យឱ្យមានសេរីភាពឡើងវិញ។ ពោលគឺមានន័យថា ជនសង្ស័យមិនត្រូវបានបញ្ជូនខ្លួនទៅកាន់ខាងមុខយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះឡើយ។ បើទោះបីជាយ៉ាងណាក៏ដោយ ការរួចផុតការចោទប្រកាន់នេះ គឺជាការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញាទៅលើបទល្មើសក្នុងការចោទប្រកាន់តែប៉ុណ្ណោះ។

### កថាខណ្ឌទី៤៖ ការទាមទារវត្ថុដែលរឹបអូសមកវិញ

នៅពេលដែលមានការរឹបអូសវត្ថុមកហើយ ប៉ុន្តែសំណុំរឿងត្រូវបានបិទបញ្ចប់ ដោយការចេញដីកាតម្កល់រឿងទុកឥតការ នោះតំណាងអយ្យការអាចចេញដីកាសម្រេចឱ្យប្រគល់វត្ថុដែលរឹបអូសនោះជូនម្ចាស់ដើមវិញ នៅពេលដែលកម្មសិទ្ធិនៃវត្ថុនោះ ពុំមានការជំទាស់។

---

[67] មាត្រា ៤១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[68] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មណទណ្ឌ ឆ្នាំ២០០៧

## ផ្នែកទី៣៖ យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ

ការប្តឹងជំទាស់នឹងការតម្កល់រឿងទុកឥតចាត់ការនេះ គឺជាយន្តការដែលសំដៅទៅលើ នីតិវិធីទាំងឡាយដែលធ្វើឡើងដើម្បីនាំឱ្យមានការចោទប្រកាន់ឡើងវិញ បន្ទាប់ពីមានការ សម្រេចតម្កល់រឿងទុកឥតចាត់ការ។

### កថាខណ្ឌទី១៖ ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ

ភាពគ្មានអាជ្ញាអស់ជំនុំជាការបើកផ្លូវមួយឱ្យ ព្រះរាជអាជ្ញាសម្រេចការចោទប្រកាន់សារជាថ្មីលើអង្គហេតុដដែល បើក្នុងករណីព្រះរាជអាជ្ញាបានរកឃើញភាពមិនប្រក្រតី ឬភស្តុតាងថ្មីណាមួយ ដែលនាំឱ្យតំណាងអយ្យការអាចកំណត់បានសញ្ញាណថ្មី និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចោទប្រកាន់នោះតំណាងអយ្យការអាចសើរើកែប្រែពីការតម្កល់រឿងទុកឥតចាត់ការ មកធ្វើការចោទប្រកាន់សារជាថ្មីឡើងវិញ លើកលែងតែករណីបទល្មើសនោះផុតរលត់បណ្តឹងអាជ្ញាតែប៉ុណ្ណោះ។ ដូច្នេះបើសិនជាបណ្តឹងអាជ្ញា មិនទាន់ផុតរលត់នៅឡើយនោះតំណាងអយ្យការ អាចសើរើ កែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើងវិញបាន។

### កថាខណ្ឌទី២៖ ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជានីតិវិធីដែលអនុញ្ញាតឱ្យ ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បើក្នុងករណីខ្លួនមិនសុខចិត្ត នឹងការសម្រេចលើពាក្យប្តឹងពាក់ព័ន្ធនឹងការសម្រេចតម្កល់រឿងទុកឥតចាត់ការពីសំណាក់តំណាងអយ្យការ។ អគ្គព្រះរាជអជ្ញាអមសាលាឧទ្ធរណ៍មានតួនាទីឃ្លាំមើលការអនុវត្តច្បាប់ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[69] ដូចនេះព្រះរាជអាជ្ញាជាអ្នកទទួល និងសម្រេចលើបណ្តឹងនៃការតវ៉ា។ បើក្រឡេកទៅមើលច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣ វិញមានលក្ខណៈស្រដៀងគ្នាទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ដែលទាក់ទងនឹងគោលបំណងនៃច្បាប់ ក៏ប៉ុន្តែច្បាប់ទាំងពីរនេះ ខុសគ្នាត្រង់ថាបណ្តឹងតវ៉ាត្រូវប្តឹងទៅសាលាឧទ្ធរណ៍[70] មិនមែនប្តឹងមកអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ទេ[71]។

កាលណាមានបណ្តឹងតវ៉ាទាមទារពី សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការសាលាដំបូង នោះអ្នកប្តឹងត្រូវដាក់ពាក្យប្តឹងសាមញ្ញមួយនៅអង្គការអយ្យការពាក់ព័ន្ធ (អង្គការអយ្យការដែលចេញសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ) ក្នុងរយៈពេលយ៉ាងយូរបំផុត ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលបានដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ជំហានបន្ទាប់ទៀត អង្គការអយ្យការ

[69] មាត្រា ៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[70] មាត្រា ៥៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣

[71] មាត្រា ៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដែលទទួលបានដំណឹងនេះ ត្រូវបញ្ជូនសំណុំរឿងបន្តភ្លាមៗទៅអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដើម្បីសម្រេច និងចេញអធិបញ្ញា។

**១. នីតិវិធីនៃការដាក់ពាក្យប្តឹងតវ៉ា**

ដើម្បីផ្តើមនីតិវិធី នៃការប្តឹងតវ៉ាទៅបានភាគីដែលកើតទុក្ខមិនសុខចិត្តនឹង សេចក្តីសម្រេចនៃការតម្កល់រឿងទុកឥតចាត់ការអាចធ្វើបណ្តឹងសាមញ្ញមួយ។ ដែលបណ្តឹងនេះ គឺប្តឹងទៅអង្គការអយ្យការ ដែលពាក់ព័ន្ធតាមដែនសមត្ថកិច្ច ពោលគឺអង្គការអយ្យការអមសាលាដំបូង ដែលបានទទួលពាក្យបណ្តឹង របស់ខ្លួនលើកទីមួយ មិនមែនសំដៅដល់ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងនោះទេ។

**២. ចំណាត់ការលើបណ្តឹងតវ៉ា**

កាលណាទទួលបានពីអ្នកប្តឹងហើយនោះ តំណាងអយ្យការអមសាលាដំបូង ត្រូវបញ្ជូនសំណុំរឿងទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីធ្វើការពិនិត្យលើបណ្តឹងនោះ។ អគ្គព្រះរាជអាជ្ញាត្រួតពិនិត្យបណ្តឹងដោយពិចារណាលើចំណុចដូចខាងក្រោម៖

– បើបណ្តឹងនោះមានមូលហេតុត្រឹមត្រូវ ស្របតាមការយល់ឃើញរបស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ នោះគាត់អាចប្រើអំណាចអធិបញ្ញាជាលាយលក្ខណ៍អក្សរ ដល់ព្រះរាជអាជ្ញាអមសាលាដំបូងដើម្បីធ្វើការចោទប្រកាន់។ មកដល់ដំណាក់កាលនេះ ព្រះរាជអាជ្ញាអមសាលាដំបូងត្រូវតែអនុវត្តតាមការស្នើរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយគ្មានសិទ្ធិអំណាចក្នុង ការតម្កល់រឿងទុកឥតចាត់ការដូចពីមុននោះទេ។

– ករណីផ្ទុយពីខាងលើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ។ បន្ទាប់មកអគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីការសម្រេចនេះទៅអ្នកប្តឹង ដោយមិនអនុញ្ញាឱ្យធ្វើការប្តឹងតវ៉ាទៀតនោះទេ។ ការជូនដំណឹងនេះ គឺដើម្បីឱ្យអ្នកប្តឹង ប្រើនីតិវិធីផ្សេងទៀតដើម្បីប្តឹងតវ៉ា តួយ៉ាងគឺការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

**កថាខណ្ឌទី៣៖ ការធ្វើអធិបញ្ញាតាមឋានានុក្រមនៃអង្គការអយ្យការ**

**១. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាសេនាធិការបស់រាជរដ្ឋាភិបាល ដែលកើតឡើងចេញពីការបោះឆ្នោត។ ក្រសួងយុត្តិធម៌បង្កើតឡើងដើម្បីពង្រឹងវិស័យច្បាប់ និងធានានូវសណ្តាប់ធ្នាប់សង្គម។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរណាមួយកើតឡើង។[72] ហេតុដូច្នេះហើយ ក្រសួងយុត្តិធម៌អាចធ្វើការប្តឹងបរិហារបទល្មើស ដែលខ្លួនបានដឹងព្រមទាំងអាចធ្វើ

[72] មាត្រា ៣៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

អធិបញ្ញាតាមការណែនាំ ជាលាយលក្ខណ៍អក្សរ និងត្រូវដាក់បញ្ជូនទៅក្នុងសំណុំរឿងឱ្យ អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានតាមការយល់ឃើញរបស់រដ្ឋមន្រ្តី ថាជាការគួរ ឬមិនគួរ។ សូមបញ្ជាក់ផងដែរថា រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងឱ្យធ្វើការតម្កល់ទុករឿងឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ មានតែការធ្វើអធិបញ្ញាឱ្យធ្វើការចោទប្រកាន់ឡើងវិញសារជាថ្មី។[73]

**២.អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានតួនាទីឃ្លាំមើលការអនុវត្តន៍ច្បាប់នៅក្នុងដែន សមត្ថកិច្ចនៃសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក៏មានអំណាចលើចៅក្រម អយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះ អគ្គព្រះរាជអាជ្ញាក៏អាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬចាត់ឱ្យចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ឃើញថាជាការគួរ។[74]

**៣. ព្រះរាជអាជ្ញាអមសាលាដំបូង**

ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញា ឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។[75] ព្រះរាជអាជ្ញានៅទីនេះគឺសំដៅដល់ព្រះរាអាជ្ញាអមសាលាដំបូង ដោយហេតុថា ព្រះរាជអាជ្ញាអមតុលាការកំពូល និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មិនមានអំណាចលើអយ្យការណាមួយក្នុងការប្រើអំណាចអធិបញ្ញាបាននោះទេ។ ព្រះរាជអាជ្ញាអមសាលាដំបូង ក៏អាចប្រើអំណាចនេះស្របទៅតាមសមត្ថកិច្ចដែនដីរបស់ខ្លួនដែលលាតសន្ធឹងត្រឹមរាជធានី-ខេត្ត។

**៣.១. អំណាចនៃអធិបញ្ញា**

**ក. ខ្លឹមសារ និង ទម្រង់នៃអំណាចអធិបញ្ញា**

អំណាចអធិបញ្ញា គឺជាបញ្ញាដែលប្រើចំពោះការចោទប្រកាន់ ប៉ុន្តែមិនមែនជាការបញ្ញាឱ្យមានការតម្កល់រឿងទុកឥតចាត់ការនោះទេ។ លុះត្រាតែអយ្យការយល់ឃើញពីការតវ៉ានាំរបស់អ្នកប្តឹង មិនសុខចិត្តចំពោះការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ដោយមានមូលហេតុត្រឹមត្រូវស្របតាមអង្គច្បាប់ ទើបអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់។[76] ដូច្នេះបើទោះជា

[73] មាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[74] មាត្រា២៩ កថាខណ្ឌ២ វាក្យខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[75] មាត្រា២៩ កថាខណ្ឌ២ វាក្យខណ្ឌ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[76] មាត្រា៤១ កថាខណ្ឌ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

មានការបញ្ជាឱ្យមានការតម្កល់រឿងទុកឥតចាត់ការណាមួយ ក៏ព្រះរាជអាជ្ញាឈរលើមូលដ្ឋាននៃឆន្ទានុសិទ្ធិរបស់ខ្លួន បូករួមទាំងការថ្លឹងថ្លែងទាំងនីតិវិធីច្បាប់ និងអង្គហេតុផ្សេងៗនៃរឿងក្តីនីមួយៗ។

ចំណែកឯទម្រង់នៃអំណាចអធិបញ្ញា គឺដាច់ខាតត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីបង្ហាញពីអំណាចចាប់បង្ខំឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់។[77] បើសិនជាទម្រង់នៃអំណាចអធិបញ្ញានេះ ធ្វើឡើងមិនមែនជាលិខិតលាយលក្ខណ៍អក្សរនោះទេ អធិបញ្ញានោះហាក់ដូចជាការណែនាំធម្មតា ដែលព្រះរាជអាជ្ញាអនុវត្តតាម ឬក៏មិនអនុវត្តតាមគឺមិនមានលក្ខណៈចាប់បង្ខំ។ ហេតុដូចនេះហើយកាលណាព្រះរាជអាជ្ញាអនុវត្តតាមអំណាចអធិបញ្ញានេះ មានន័យថាខ្លួនបានពិនិត្យមើលត្រឹមត្រូវ ដោយយកមូលដ្ឋានច្បាប់ជាគោលក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ។

### កថាខណ្ឌទី៤៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ជាគោលការណ៍បណ្តឹងរបស់ជនរងគ្រោះគ្រាន់តែជាបណ្តឹងទាមទារ ឬហៅម្យ៉ាងទៀតជា បណ្តឹងសាមញ្ញ ដែលគ្មានអានុភាពនាំឱ្យមានការចោទប្រកាន់ព្រហ្មទណ្ឌឡើយ មានតែព្រះរាជអាជ្ញា តែប៉ុណ្ណោះដែលអាចធ្វើឱ្យបណ្តឹងមានដំណើរការឡើងវិញបាន។[78] ប៉ុន្តែច្បាប់ក៏មានចែងនូវ អញ្ញត្រកម្ម មួយអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ពោលគឺ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាច ដាក់ពាក្យបណ្តឹងអាជ្ញាឱ្យមានដំណើរការបានតាមរយៈ ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខនៃចៅក្រមស៊ើបសួរផ្ទាល់[79] នេះគឺជាការបើកផ្លូវដល់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការដាក់ពាក្យប្តឹង ក្នុងករណីរឿងក្តីត្រូវបានព្រះរាជអាជ្ញាតម្កល់ទុកឥត ចាត់ការ។

## ផ្នែកទី៤៖ ផលវិបាកនៃការតម្កល់រឿងទុកឥតចាត់ការ

ចំពោះការសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ ជានីតិវិធីយ៉ាងសំខាន់មួយនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ ការសម្រេចតម្កល់រឿងទុកឥតចាត់ការ គឺត្រូវឈរលើសំអាងច្បាប់ និងសំអាងហេតុត្រឹមត្រូវ ដើម្បីបម្រើផលប្រយោជន៍ដល់សង្គម។ ទោះបីជាយ៉ាងណាក៏ដោយ ទន្ទឹមនឹងគុណសម្បត្តិមួយចំនួន ការតម្កល់រឿងទុកឥតចាត់ការ ក៏បានផ្តល់នូវគុណវិបត្តិផងដែរ បើកាលណាមានការខ្វះចន្លោះប្រហោង នៃអង្គច្បាប់ និងអង្គហេតុ។

[77] មាត្រា៤១ កថាខណ្ឌ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[78] មាត្រា ៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[79] មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

**កថាខណ្ឌទី១៖ គុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការ**

កាលណាការអនុវត្តនីតិវិធីនៃ ការតម្កល់រឿងទុកឥតចាត់ការនេះបានល្អ គឺអាចផ្តល់នូវផលប្រយោជន៍ជាច្រើនដល់សង្គមជាតិ៖

– ចៅក្រមអយ្យការនឹងខិតខំប្រើប្រាស់ នូវធនធានចំណេះដឹងរបស់ខ្លួនឱ្យ អស់ពីសមត្ថភាពដើម្បីបំពេញតួនាទីជាគម្រូដ៏ល្អនៅក្នុងសង្គម។

– កាត់បន្ថយការកកស្ទះសំណុំរឿងនៅដំណាក់កាលស៊ើបសួរ ឬជំនុំជម្រះ ដោយហេតុថាចៅក្រមអយ្យការបានថ្លឹងថ្លែងប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការជម្រះចោល ចំពោះបទល្មើសតូចតាចមួយចំនួនដែលបង្កព្យសនកម្មក្នុងរូបភាពតិចតួចដល់សង្គម ជាជាងចំណាយពេល លើរឿងក្តីដែលស្មុកស្មាញមកដោះស្រាយ។ ម៉្យាងវិញទៀត ការតម្កល់រឿងទុកឥតចាត់ការក៏អាចជួយសម្រាលបន្ទុកចំពោះ ការកកស្ទះពាក្យបណ្តឹងទៅតុលាការ ដោយទុកពេលវេលា និងលទ្ធភាពតុលាការយកចិត្តទុកដាក់ទៅលើ តែបទល្មើសណាដែលបង្កព្យសនកម្មធ្ងន់ធ្ងរទៅដល់សង្គមជាតិ ឬគ្រោះថ្នាក់ហានិយភ័យសម្រាប់ប្រទេសជាតិទាំងមូល។ ការធ្វើបែបនេះនឹង នាំឱ្យការដំណើររឿងក្តីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងធានាបាននូវយុត្តិធម៌ដល់សង្គម។ ជាការអនុវត្តជាក់ស្តែង ក្រសួងយុត្តិធម៌បានបង្កើតឡើងនូវ យុទ្ធនាការទ្រង់ទ្រាយធំទៅលើការដោះស្រាយនូវការកកស្ទះសំណុំរឿងដែលនៅក្នុងតុលាការ ហើយមានរយៈពេល ២២២ថ្ងៃនៅតាមសាលាដំបូងរាជធានី-ខេត្ត។[80] ដោយយោងទៅតាមទិន្នន័យរបស់ក្រសួងយុត្តិធម៌នៅចុង ឆ្នាំ២០២០ កន្លងទៅការដោះស្រាយការកកស្ទះសំណុំរឿងនៅក្នុងតុលាការ និងការកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ ក្រសួងបានដោះស្រាយបាន ៣៥.១០០សំណុំរឿង ស្មើនឹង ៨៩ភាគរយ។ ក្រៅពីនេះ តាមរយៈយុទ្ធនាការដដែល ក្រសួងយុត្តិធម៌ ក៏បានបន្តដោះស្រាយសំណុំរឿងព្រហ្មទណ្ឌថ្មីចំនួន ៣៦.៥០០សំណុំរឿងទៀត។[81]

– ការកាត់បន្ថយភាពណែនចង្អៀតនៅពន្ធនាគារ ក៏ជាផ្នែកមួយដែលការតម្កល់រឿងទុកឥតចាត់ការផ្តល់ផលវិជ្ជមានដែរ ពីព្រោះកាលណាបើគ្មានការចោទប្រកាន់ ក៏គ្មានឡើយនូវការឃុំខ្លួន បណ្តោះអាសន្ន ហើយអាចគ្មានការប្រកាសពិរុទ្ធភាព និងទោសផងដែរ។ ម៉្យាងវិញទៀត ការផ្តល់លទ្ធភាពឱ្យសង្គមជាតិកសាងនូវធនធានមនុស្សដោយរូបភាពអប់រំ នោះក៏អាចជាកម្លាំងចលករដល់ការអភិវឌ្ឍន៍ជាតិ។ ដោយឡែកបទល្មើសទាំងអស់មិនប្រាកដថា សុទ្ធតែបានបំពាន ឬផ្តល់ព្យសនកម្មខ្លាំងក្លាដល់ផលប្រយោជន៍របស់បុគ្គល និងសន្តិសុខសង្គមនោះទេ។ ការសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះអំពើល្មើសទាំងនោះ មានន័យថា

---

[80] សេចក្តីប្រកាសពត៌មានស្តីពី លទ្ធផលរយៈពេល២២២ថ្ងៃ នៃការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលារាជធានី ខេត្ត ចេញពីក្រសួងយុត្តិធម៌ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០

[81] ការចុះផ្សាយរបស់ វិទ្យុបារាំងអន្តរជាតិ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០២១

ស្ថាប័នតុលាការ បានផ្តល់ឱកាសឱ្យជនទាំងនោះបានកែប្រែខ្លួន ក៏ដូចជាបានលើកទឹកចិត្តឱ្យសង្គមទាំងមូលមានការរួបរួមគ្នា ដើម្បីការអភិវឌ្ឍន៍ធនធានមនុស្ស ជាជាងដែលទុកជនទាំងនោះ ក្នុងពន្ធនាគារដោយមិនបានផ្តល់ផលប្រយោជន៍ និងថែមទាំងជាបន្ទុករបស់រដ្ឋក្នុងការចំណាយថវិកាទៀតផង។

– កាត់បន្ថយការប្រើប្រាស់ធនធានថវិការដ្ឋច្រើនហួសប្រមាណ ជាងតម្រូវការចាំបាច់ ដែលរដ្ឋត្រូវមានទំនួលខុសត្រូវជាងគេ។ ការធ្វើបែបនេះនឹងនាំឱ្យការចំណាយលើថវិការដ្ឋមានប្រសិទ្ធភាព។

**កថាខណ្ឌទី២៖ គុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការ**

ទន្ទឹមនឹងផលប្រយោជន៍ក៏ដូចជាគុណសម្បត្តិ នៃការតម្កល់រឿងទុកឥតចាត់ការ ការអនុវត្តន៍នីតិវិធីនេះក៏អាចកើតមាននូវគុណវិបត្តិ ឬផលអវិជ្ជមានមួយចំនួនផងដែររួមមានជាអាទិ៍៖

– ការដែលអំណាចឆន្ទានុសិទ្ធិទាំងមូលក្នុង ការតម្កល់រឿងទុកឥតចាត់ការ ត្រូវបានផ្តល់ទៅឱ្យស្ថាប័នអយ្យការ ដោយពុំមានច្បាប់ចែងច្បាស់លាស់អំពីលក្ខខណ្ឌក្នុងការតម្កល់រឿងទុកឥតចាត់ការ ធ្វើឱ្យតំណាងអយ្យការ កាន់តែមានអំណាចកាន់តែច្រើន។

– មួយវិញទៀត ការតម្កល់រឿងទុកឥតចាត់ការ ជាហេតុនាំឱ្យមានអំពើល្មើសតូចៗជាច្រើនដែលបង្កផលរំខានដល់សន្តិសុខសង្គម ដោយបុគ្គលម្នាក់ៗលែងខ្លាចរអាការផ្តន្ទាទោស ដោយច្បាប់ព្រហ្មទណ្ឌឡើយ។

–ជនរងគ្រោះនៃអំពើល្មើសនោះផ្ទាល់ ពុំអាចទទួលបាននូវយុត្តិធម៌ពីការរងផលប៉ះពាល់ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលបានសំណងនៃការខូចខាតពីតុលាការព្រហ្មទណ្ឌ ដោយហេតុថាគ្មានការប្រកាសទោសពីសំណងរដ្ឋប្បវេណីណាមួយឡើយ កាលណាគ្មានការប្រកាសពីពិរុទ្ធភាព។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវពីប្រធានបទ ការតម្កល់រឿងទុកឥតចាត់ការ ដោយបកស្រាយ ដកស្រង់ចេញពីលិខិតបទដ្ឋានគតិយុត្ត វិធានច្បាប់ និងទ្រឹស្តីដែលពាក់ព័ន្ធជាច្រើនមកនេះ យើងសន្និដ្ឋានបានថា របាយការណ៍សិក្សាស្រាវជ្រាវនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងសម្រាប់ជាកូនសោរ ដល់អ្នកសិក្សាក្រោយៗ ក្នុងការទាញយកចំណេះដឹងនៃនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ។ លើសពីនេះទៅទៀត ប្រធានបទនេះពិតជាបានឆ្លុះបញ្ចាំងយ៉ាងលម្អិតអំពី តួនាទីនៃស្ថាប័នអយ្យការ ជាពិសេសគឺព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានប្រគល់សិទ្ធិអំណាចជូន តួយ៉ាងក្រសួងយុត្តិធម៌ក៏មានវត្តមានក្នុងការធ្វើអធិបញ្ញាផងដែរក្នុងដំណើរការ តម្កល់រឿងទុកឥតចាត់ការ។

យើងសង្កេតឃើញផងដែរថា ការតម្កល់រឿងទុកឥតចាត់ការ គឺពិតជាបានជះឥទ្ធិពលដល់ការ រីកចម្រើនរបស់សង្គម តាមរយៈគោលការណ៍ប្រៀនប្រដៅបែបអប់រំ។ មួយវិញទៀត ព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការដោយស្របតាមទម្រង់ដែលណែនាំ ដោយក្រសួងយុត្តិធម៌ និងវិធានទ្រឹស្តីពាក់ព័ន្ធ ពោលគឺមិនមានបទប្បញ្ញត្តិណាចែងជាក់លាក់នៅក្នុងបទដ្ឋានគតិយុត្តឡើយ។ យ៉ាងណាមិញ ចំពោះមធ្យោបាយនៃកិច្ចចោទប្រកាន់របស់តំណាងអយ្យការវិញ គឺមានបទប្បញ្ញត្តិជាក់លាក់កំណត់យ៉ាងច្បាស់ និងលម្អិត ហើយតំណាងអយ្យការអាចពិនិត្យថ្លឹងថ្លែង និងពិចារណាថា តើគប្បីប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីសាកសមនឹងសំណុំរឿងជាក់ស្តែង។

សរុបសេចក្តីមក អង្គការអយ្យការ គឺជាតួអង្គសំខាន់ ដែលមិនអាចខ្វះបានក្នុងដំណើរការក្តីព្រហ្មទណ្ឌនៅតុលាការកម្ពុជា។ ជាពិសេសនោះ គឺនីតិវិធីក្នុងការតម្កល់រឿងទុកឥតចាត់ការនេះតែម្តង បើគ្មានកិច្ចអន្តរាគមន៍ក៏ដូចជាការចូលរួមនានាទៅតាមតួនាទីពីសំណាក់អង្គការអយ្យការ តាមការកំណត់របស់ច្បាប់នោះ ម្លោះហើយដំណើរការរីកចម្រើននៃវិស័យច្បាប់របស់កម្ពុជាយើង ក៏មិនអាចដើរទៅមុខដោយរលូនបានឡើយ។

# អនុសាសន៍

## អនុសាសន៍

ដើម្បីចូលរួមចំណែកក្នុងការអនុត្តន៍ជាក់ស្តែង នៃវិស័យច្បាប់នៅកម្ពុជាឱ្យកាន់តែល្អប្រសើរ និងមានគុណភាព យើងខ្ញុំជឿជាក់ថា អ្នកអនុវត្តច្បាប់ទាំងអស់ចូលរួមសាមគ្គីគ្នា ស្រលាញ់យុត្តិធម៌ មានមនសិកាស្នេហាជាតិ ចូលរួមពិភាក្សាផ្លាស់ប្តូរឆន្ទៈគ្នាទៅវិញទៅមក ដើម្បីទទួលបាននូវសមិទ្ធផល មួយដ៏ល្អប្រសើរ ព្រមទាំងរីករាយនឹងបម្រើសង្គមជាតិ។ កាលបើបានចូលរួមបែបនេះ យើងខ្ញុំជឿជាក់ថា ភាពអយុត្តិធម៌ក្នុងសង្គមនឹងកាត់បន្ថយ។ ហេតុដូចនេះហើយក្នុងនាម យើងខ្ញុំជាអ្នកសិក្សាផ្នែកច្បាប់ជំនាន់ថ្មីនេះ មានជាអនុសាសន៍មួយចំនួន អាចនឹងយកទៅអនុវត្តបាន និងជាការពិចារណាដល់អ្នកអនុវត្តន៍ច្បាប់ទាំងឡាយ ជាពិសេសគឺអ្នកសិក្សាផ្នែកច្បាប់ជំនាន់ក្រោយៗទៀតនៅក្នុងប្រទេសយើង។ អនុសាសន៍ទាំងនោះរួមមាន ៖

❖ ពង្រឹងសមត្ថភាពធនធានមនុស្ស នៅក្នុងវិស័យនីតិសាស្ត្រ និងធានាការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌។ អ្វីដែលសំខាន់នោះគឺ ធ្វើការផ្សព្វផ្សាយ និងផ្តល់វគ្គបណ្តុះបណ្តាលក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាទ្រឹស្តីច្បាប់ផ្សេងៗដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋគ្រប់រូប។ មន្ត្រីនគរបាលយុត្តិធម៌ដែលជាអ្នកអនុវត្តច្បាប់ភាគច្រើន នៅតាមមូលដ្ឋាន ត្រូវតែយល់ច្បាស់ពីតួនាទី ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានចែង ក្នុងគោលបំណងជៀងវាងការបំពេញភារកិច្ចណាមួយមិនបានត្រឹមត្រូវ ដែលអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសភារកិច្ចថ្នាក់លើ មានដូចជាព្រះរាជអាជ្ញាជាដើម។

❖ លើកទឹកចិត្តដល់មន្ត្រីដែលមានតួនាទី និងភារកិច្ចក្នុងប្រព័ន្ធយុត្តិធម៌ តាមរយៈការតំឡើងប្រាក់បៀវត្ស ឱ្យបានសមរម្យដោយគិតលើជីវភាពរស់នៅប្រចាំថ្ងៃ។ ការដែលធ្វើបែបនេះ នឹងអាចជួយកាត់បន្ថយអំពើពុករលួយ កើតមានឡើងនៅក្នុងប្រព័ន្ធតុលាការ ដោយហេតុថា ការទទួលបានប្រាក់បៀវត្សតិចតួចក៏អាចជាកត្តាមួយនាំឱ្យប៉ះពាល់ដល់កម្រិតជីវភាពរបស់មន្ត្រីដែរ។ ដូចនេះមន្ត្រីមួយចំនួនចង់ ឬមិនចង់ក៏អាចក្បត់ឧត្តមគតិខ្លួន មនសិការវិជ្ជាជីវៈ ដោយសារអំពើកេងប្រវ័ញ្ចពុករលួយជាដើម។ ដើម្បីធានានូវយុត្តិធម៌ដល់មនុស្សគ្រប់គ្នាក្នុងសង្គម និងកាត់បន្ថយអំពើពុករលួយការតំឡើងប្រាក់បៀវត្ស គឺពិតជាសំខាន់ខ្លាំងណាស់ក្នុងប្រព័ន្ធតុលាការ។

❖ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែ មានសមត្ថកិច្ចក្នុងការគ្រប់គ្រងថវិកា ដោយឡែករបស់សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល។ នៅពេលដែលកញ្ចប់ថវិកាទទួលបានពីក្រសួងយុត្តិធម៌ អាចនឹងកើតមាននូវការកេងចំណេញផលប្រយោជន៍ណាមួយ ដោយសារតែក្រសួងយុត្តិធម៌អាចធ្វើការទៅលើសាលាដំបូងនិងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល។ ដូចចែងក្នុង មាត្រា ៧៩ នៃច្បាប់ស្តីពី ការរៀបចំអង្គការ

តុលាការប្រកាសឱ្យប្រើថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ លើកឡើងថា "សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលបានវិភាជន៍ពីកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌" ។

- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែពិនិត្យ តាមដានឱ្យបានល្អិតល្អន់ គ្រប់ជ្រុងជ្រោយអំពីសកម្មភាពរបស់អយ្យការគ្រប់ជាន់ថ្នាក់ និងត្រូវអនុវត្តនីតិវិធីពិន័យភ្លាមៗចំពោះតំណាងអយ្យការណាដែលប្រព្រឹត្តខុសនូវកំហុសធ្ងន់ធ្ងរ ដែលអាចប៉ះពាល់ដល់វិស័យយុត្តិធម៌។

- ដោយហេតុឃើញថាការតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការ គឺមិនមានច្បាប់ណាមួយចែងច្បាស់លាស់នោះទេ តំណាងអយ្យការត្រូវតែធ្វើការតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកទៅលើសំអាងច្បាប់ និងសំអាងហេតុត្រឹមត្រូវ និងយល់ច្បាស់ពីគោលការណ៍ការលានុវត្តភាពនៃការចោទប្រកាន់ ដើម្បីធានាឱ្យមានភាពងាយស្រួលដល់ ការសម្រេចតម្កល់រឿងទុកឥតចាត់ការមិនមានផលប៉ះពាល់ដល់ផលប្រយោជន៍ទូទៅ និងបុគ្គលដែលពាក់ព័ន្ធជាដើម។

# ឯកសារយោង

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩
- ច្បាប់ស្តីពីព្រៃឈើ ប្រកាសឱ្យប្រើ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ សម្រេចប្រកាសឱ្យប្រើ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥
- ច្បាប់ស្តីពីឯកពន្ធភាព សម្រេចប្រកាសឱ្យប្រើ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៦
- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សម្រេចប្រកាសឱ្យប្រើ ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា សម្រេចឱ្យប្រើ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក សម្រេចប្រកាសឱ្យប្រើ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន សម្រេចប្រកាសឱ្យប្រើ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦
- ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់។
- ព្រះរាជក្រឹត្យលេខ នស/រកត/១៣០០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ដំណើរការសាលាដំបូងឧទ្ធរណ៍ភ្នំពេញនិងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ
- ព្រះរាជក្រឹត្យលេខ នស/រកត/១៣០១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដំណើរការសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ
- ព្រះរាជក្រឹត្យលេខ នស/រកត/១៣០២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង
- ព្រះរាជក្រឹត្យលេខ នស/រកត/១៣០៣ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍ព្រះសីហនុនិងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ
- សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលរយៈពេល ២២២ថ្ងៃ នៃការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត ប្រកាសថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

# ឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធ

- ដីកាតម្កល់រឿងទុកឥតចាត់ការ
- លិខិតជូនដំណឹងពីការតម្កល់រឿងទុកឥតចាត់ការ
- ពាក្យបណ្ដឹងឧទ្ធរណ៍ និងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ
- លិខិតប្រគល់ប្ដឹងលើឧទ្ធរណ៍លើដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ
- អំណាចអធិបញ្ញាពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តកំពង់ឆ្នាំង**
លេខ ២២៨៤ អ.យ/២០២០

# ដីកាតម្កល់រឿងទុកឥតចាត់ការ

**យើង** **តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២០២ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងកស្តុតាងនានា។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា :

១ . អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្តឹង

៣.២ ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្របសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

---

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

៤.២. ☐ ការបោះបង់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹង[2]

៤.៣. ☐ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការទទួលខុសត្រូវ

៤.៤. ☐ ការខកខានរបស់ដើមបណ្ដឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. ☐ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[3]

៤.៨. ☐ ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ / ដល់អនីតិជន

៥.២. ☐ សន្ធានកម្ម[4]

៥.៣. ☐ អធិបញ្ញាផ្ដល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្ដឹងបោះបង់បណ្ដឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសំណើររបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរលឹកពីអត្ថបទច្បាប់ / ការព្រមាន[5]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧.ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្ដល់ជំនួយការអប់រំជំនួយការចោទប្រកាន់

**ការសង្កេតផ្សេងៗ** : កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ ភេទប្រុស អាយុ ៣៤ ឆ្នាំ បានដាក់ពាក្យបណ្ដឹងចូលប៉ុស្ដិ៍នគរបាលរដ្ឋបាលលង្វែក ពីបទៈលួច (លុយ) ប្ដឹងឈ្មោះ ភេទប្រុស អាយុ ១៣ឆ្នាំ បានធ្វើសកម្មភាពលួចលុយចំនួន៧,៣០០ ដុល្លារអាមេរិក ។

**បានឃើញ** : ពាក្យបណ្ដឹងចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ ។

---

២ដើមបណ្ដឹងឈប់ប្ដឹង

៣សកម្មភាពរបស់ជនល្មើសបានបញ្ឈប់បទល្មើស នឹងស្ដារស្ថានភាពឡើងវិញ

៤ករណីចែងដោយច្បាប់

៥ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានអោយឈប់ប្រព្រឹត្ត

៦ករណីចែងដោយច្បាប់

**បានឃើញ** : ចម្លើយរបស់ឈ្មោះ នៅចំពោះមុខអធិការនគរបាលថា៖ កាលពីខែសីហា ឆ្នាំ២០១៩ ខ្លួននិងប្រពន្ធមានសុំខ្ចីលុយ ធនាគារ អេស៊ីលីដាចំនួន១៥,០០០ដុល្លារ ដើម្បីយកមកសាងសង់ផ្ទះ ហើយបានចំណាយទិញសម្ភារៈនៅសល់ចំនួន ៧,៣០០ដុល្លារ ខ្លួននិងប្រពន្ធបានយកទុកក្នុងប្រអប់ទូរស័ព្ទរួចយកទៅទុកដាក់ក្នុងទូរគ្រណាត់ជាមួយខោរអាវ។ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ៧យប់ ប្រពន្ធខ្លួនបានរាប់លុយឃើញគ្រប់ចំនួន៧,៣០០ដុល្លារ។ លុះមកដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង ៤និង៣០នាទីរសៀល ខ្លួនបានចាក់សោរចូលផ្ទះក្នុងបន្ទប់ ស្រាប់តែឃើញរូតទូរខោអាវចំហរ នឹងខោអាវរាយប៉ាយ លើពូក ហើយប្រអប់ទូរស័ព្ទដាក់លុយនោះរបើកចេញពីគ្នា បាត់លុយដែលខ្លួនទុកនោះទាំងអស់ ហើយខ្លួនបានសាកសួរអ្នកជិតខាង គេប្រាប់ថាមានក្មេងម្នាក់ ឈ្មោះ ទើបមកស្នាក់នៅ ដើរចូលនឹងចេញពីផ្ទះខ្លួន ម្យ៉ាងទៀតក្មេងប្រុសឈ្មោះ ថា សំណាង ធ្លាប់ចេញចូលផ្ទះរបស់ខ្លួន។

**បានឃើញ** : ចម្លើយរបស់ឈ្មោះ នៅចំពោះមុខអធិការនគរបាល៖ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង១៩:០០នាទី ខ្លួននឹងប្តី បានរាប់លុយដាក់ក្នុងប្រអប់ទូរស័ព្ទ ដែលបានខ្ចីពីធានាគារចំនួន៧,៣០០ដុល្លា (ប្រាំពីរពាន់បីរយដុល្លា) យកទៅទុកក្នុងទូរដាក់ខោអាវ រួចក៏ដេកទៅ។ លុះមកដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង១៦:៣០នាទី ពេលខ្លួនចេញពីធ្វើការរោងចក្រមកផ្ទះវិញ ហើយបានចាក់សោរចូលទៅក្នុងបន្ទប់ ស្រាប់តែឃើញរូតទូរខោអាវចំហរ នឹងខោអាវរាយប៉ាយ លើពូក ហើយប្រអប់ទូរស័ព្ទដាក់លុយនោះ របើចេញពីគ្នា ភ្លាមនោះខ្លួនរកមើលលុយ ស្រាប់បាត់លុយចំនួន៧,៣០០ដុល្លា (ប្រាំពីរពាន់បីរយដុល្លា) ដែលខ្លួនទុកនោះទាំងអស់ ហើយខ្លួនបានសួរទៅប្តីរឿងបាត់លុយ គាត់តបថា អត់បានយកទេ បន្ទាប់មកមានឈ្មោះ ។ បានប្រាប់ថា ឃើញក្មេងម្នាក់ ឈ្មោះ ទើបមក ស្នាក់នៅ ដើរចូលនឹងចេញពីផ្ទះខ្លួន ម្យ៉ាងទៀតក្មេងប្រុសឈ្មោះ ថា សំណាង ធ្លាប់ចេញចូលផ្ទះរបស់ខ្លួន។

**បានឃើញ** : ចម្លើយរបស់ឈ្មោះ នៅចំពោះមុខអធិការនគរបាលថា៖ កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១៥:៣០នាទី ខ្លួនជិះម៉ូតូត្រឡប់ពីកាត់សក់ ទៅផ្ទះខ្លួនវិញ ពេលមកដល់មុខផ្ទះឈ្មោះ ដែលមានប្រពន្ធឈ្មោះ បានឃើញក្មេងប្រុសម្នាក់ឈ្មោះ ដើរចេញពីផ្ទះក្បែរបង ក្នុងដៃមានកាន់អ្វីមួយ ដាក់ក្នុងអាវចូលទៅផ្ទះរបស់វា លុះដល់ល្ងាចថ្ងៃដដែល ពេលប្រពន្ធម្ចាស់ផ្ទះ មកដល់បានច្រូលច្របល់ ទើបដឹងថា បាត់លុយដុល្លាអស់ជាច្រើន ពីក្នុងបន្ទប់ ពេលឈ្មោះ មកស្នាក់នៅភូមិវត្ត ឃុំលង្វែក គឺឈ្មោះ ធ្លាប់លួចលុយគេ និងគាស់ហ៊ីបពុទ្ធបូជា នៅវត្តទៀតផង។

**បានឃើញ** : ចម្លើយរបស់ឈ្មោះ នៅចំពោះមុខអធិការនគរបាលថា៖ ខ្លួនបានមកស្នាក់នៅជាមួយឈ្មោះ រស់នៅភូមិវត្ត ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ខ្លួនតែងតែមកលេង និងចេញចូលផ្ទះរបស់ឈ្មោះ ម៉ឺង ចន្ថា ព្រមទាំងបានមកមើលទូរស្សន៍ នៅ

ផ្ទះគាត់ទៀតផង។ លុះមកដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១៣:០០នាទី ខ្លួនបាន ចូលទៅផ្ទះរបស់ឈ្មោះ ហើយអង្គុយមើលទូរទស្សន៍ជាមួយក្មួយម្ចាស់ផ្ទះ ប្រហែល២ម៉ោង ទើបខ្លួនឈប់មើល ហើយទូរទស្សន៍ម្ចាស់ទុកនៅខាងក្រៅ ខ្លួនអង្គុយលើបង់បេតុង ពេលខ្លួនដើរចេញ បានឃើញជណ្តើរដែកដាក់បង្អួចអាចចូលទៅក្នុងបន្ទប់បាន រួចខ្លួនបានយកជណ្តើរនោះមកដាក់ខាង មុខវិញ។

**បានឃើញ** : ឯកសារផ្សេងទៀតនៅក្នុងសំណុំរឿងនេះ ។

**<u>យល់ឃើញថា:</u>**

-កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង១៥:៣០នាទី ចំណុចផ្ទះរបស់ឈ្មោះ ស្ថិតក្នុងភូមិវត្ត ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កើតមានករណី: អំពើលួច (លុយ) ដែល បង្កឡើងដោយជនសង្ស័យឈ្មោះ បណ្តាលឲ្យឈ្មោះ បាត់បង់លុយចំនួន ៧,៣០០ដុល្លា (ប្រាំពីរពាន់ដុល្លា) ប្រាកដមែន។

-យោងតាមមាត្រា២៧ កថាខណ្ឌ១ នៃច្បាប់ស្តីពីយុត្តិធម៌ អនីតិជនបានចែងថា៖ ក្នុងករណី អនីតិជនមានអាយុក្រោម១៤ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះ ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែល ច្បាប់បានកំណត់វិញភ្លាម។

-គប្បីតំណាងអយ្យការធ្វើការតម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ២០២ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ ២០២០ ទុកឥតចាត់ការ តាមមាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**<u>ដូច្នេះសម្រេច:</u>**

តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ២០២ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ របស់អយ្យការអម សាលាដំបូងខេត្តកំពង់ឆ្នាំង ទុកឥតចាត់ការតទៅ ។

ថ្ងៃពុធ ១២ កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

កំពង់ឆ្នាំង ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២០

**ព្រះរាជអាជ្ញារង**

# ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកណ្ដាល

លេខ: ... . លជណ

# លិខិតជូនដំណឹង[1]

**យើង ... តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្ដាល**

ផ្ដល់ជូនមកឈ្មោះ ... ភេទស្រី អាយុ ... ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ១៣៣ ផ្លូវលំ ភូមិហ៊ុី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ **ដើមបណ្ដឹងរដ្ឋប្បវេណី ។**

ក្បែតពាក្យបណ្ដឹងចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ របស់លោកស្រីដែលបានប្ដឹងពីឈ្មោះ ... និងឈ្មោះ ... ពាក់ព័ន្ធនឹងករណី **ហិង្សាដោយចេតនា និង ក្លែងបន្លំឯកសារ** កើតឡើងនៅភូមិស្ទឹង ឃុំលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១។

នោះយើងបានសម្រេចតម្កល់ទុកឥតចាត់ការ នូវសំណុំរឿងព្រហ្មទណ្ឌលេខ: **៣៤៨អ.ក** ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ តាមដីកាសម្រេចលេខ:៣១៧.ដកមចក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ រួចហើយ។

ប្រសិនបើអ្នកមិនសុខចិត្ត លោកមានសិទ្ធិប្ដឹងតវ៉ាទៅនឹង ដីកាតម្កល់រឿងទុកឥតចាត់ការខាងលើក្នុងរយៈពេល ២ ខែ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងនេះ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ខេត្តកណ្ដាល ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២១

តំណាងអយ្យការ

[1] ជូនដំណឹងដោយមាត្រា ៦ និងមាត្រា៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧

# ឧបសម្ព័ន្ធទី៣

ព្រះរាជាណាចក្រកម្ពុជា

ការិយាល័យមេធាវី.................. ជាតិ សាសនា ព្រះមហាក្សត្រ គំរូបមន្តទី ១៧

លេខ:...............

# ពាក្យបណ្តឹងឧទ្ធរណ៍នឹងដីកាសម្រេចតម្កល់រឿងឥតចាត់ការ

ខ្ញុំមេធាវី.............................. អត្តលេខ:............... សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ:.............................................................. ត្រូវជា.............................. ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ.................. ចុះថ្ងៃទី...... ខែ........ ឆ្នាំ.......... របស់សាលាដំបូង.................................................. ។

## សូមគោរពជូន

## លោកព្រះរាជអាជ្ញាអមសាលាដំបូង..............................................................

**កម្មវត្ថុ:** សុំប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចតម្កល់រឿងឥតចាត់ការលេខ.................. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ.................. របស់ព្រះរាជអាជ្ញាអមសាលាដំបូង.......................................................... ។

<u>**យោង:**</u> - ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧

* មាត្រា ៤១ ចែងថា ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។

- សំណុំរឿងព្រហ្មទណ្ឌលេខ.............................. ចុះថ្ងៃទី.......... ខែ.................. ឆ្នាំ..................
- ដីកាសម្រេចតម្កល់រឿងឥតចាត់ការលេខ.............................. ចុះថ្ងៃទី........ ខែ.......... ឆ្នាំ..........
- លិខិតប្រគល់សិទ្ធិប្តឹងឧទ្ធរណ៍ចុះថ្ងៃទី........ ខែ.............. ឆ្នាំ....................

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន.............................. ជ្រាបថា: នៅថ្ងៃទី...... ខែ............ ឆ្នាំ............ ព្រះរាជអាជ្ញាអមសាលាដំបូង.............................. បានចេញដីកាសម្រេចតម្កល់រឿងឥតចាត់ការលេខ.................... លើឈ្មោះ .............................. ជាជនប្រព្រឹត្តល្មើស។

ករណីនេះឈ្មោះ:.............................. ជាកូនក្តីខ្ញុំ មិនសុខចិត្តនឹងដីកាសម្រេចតម្កល់រឿងឥតចាត់ការនេះ ។ ដោយមូលហេតុ ដូចខាងក្រោមនេះ: ............................................................................................................................................................................................................................................... ។

អាស្រ័យហេតុនេះសូមលោក.............................................................. មេត្តាទទួលបណ្តឹងឧទ្ធរណ៍តាមនីតិវិធីនៃច្បាប់ដោយក្តីអនុគ្រោះ។

សូមលោក ........................................................................ ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ.................... ថ្ងៃទី........ ខែ........ ឆ្នាំ..........

ហត្ថលេខា និងត្រា

---

អាសយដ្ឋានផ្ទះលេខ.......... ផ្លូវ.............. ភូមិ.................... ឃុំ/សង្កាត់.............................. ស្រុក/ខណ្ឌ.................... ខេត្ត/រាជធានី..........

ទូរស័ព្ទ:............................ ទូរសារ:............................ អ៊ីម៉ែល:..............................................

# ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

រូបមន្តទី ២៤

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតប្រគល់សិទ្ធិប្ដឹងឧទ្ធរណ៍លើដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ……………………………… អាយុ………ឆ្នាំ ជនជាតិ……… សញ្ជាតិ……… អាស័យដ្ឋានផ្ទះលេខ………ផ្លូវលេខ………ភូមិ…………………………ឃុំ/សង្កាត់………………………… ស្រុក/ខ័ណ្ឌ…………………………ខេត្ត/រាជធានី……………………មុខរបរ…………………………………… កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ…………………………ត្រូវជា……………………………………។

**សូមប្រគល់សិទ្ធិជូន**

លោក/លោកស្រីមេធាវី……………………………អត្តលេខ…………ការិយាល័យ……… ………… ដើម្បីប្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចតម្កល់រឿងឥតចាត់ការលេខ………ចុះថ្ងៃទី……ខែ………ឆ្នាំ……… របស់តំណាងអយ្យការអមសាលាដំបូង…………………………………………។

ចាប់ពីថ្ងៃខ្ញុំបាទ/នាងខ្ញុំចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃនេះតទៅគឺលោក/លោកស្រីមេធាវីមានសិទ្ធិប្ដឹងឧទ្ធរណ៍លើដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការខាងលើនេះ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅថ្ងៃទី………… ខែ………… ឆ្នាំ……………

**បានឃើញ និងយល់ព្រម**

**ស្នាមម្រាមដៃ**

**ថ្ងៃទី…………ខែ…………ឆ្នាំ…………**

**ហត្ថលេខា និងត្រា**

# ឧបសម្ព័ន្ធទី៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ: ...

ថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**ឯកឧត្តម ... ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ៖** សំណើចាត់វិធានការផ្លូវច្បាប់ជាបន្ទាន់ និងតឹងរឹងបំផុតលើឈ្មោះ ... ចំពោះករណីប្រមាថយ៉ាងធ្ងន់ធ្ងរចំពោះអង្គព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

**យោង ៖** - មាត្រា៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- មាត្រា៤៣៧ ស្ទួន នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- មាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមព្រះរាជអាជ្ញា** ជ្រាបថា ឈ្មោះ ... បានបង្ហោះសារតាមរយៈគណនី Facebook របស់ខ្លួនកាលពីថ្ងៃទី ... ២០ ដែលមានខ្លឹមសារថា ... ។ ខ្លឹមសារនៃសារដែលឈ្មោះ ... បាននិងកំពុងផ្សព្វផ្សាយជាសាធារណៈតាមរយៈបណ្ដាញសង្គមនេះ គឺជាការប្រមាថចំពោះអង្គព្រះមហាក្សត្រ ដោយបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេចក្ដីថ្លៃថ្នូរ និងព្រះកិត្តិនាមរបស់ **ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស។ ទង្វើនេះគឺជាការរំលោភបំពានលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិនៃមាត្រា៤៣៧ ស្ទួន នៃក្រមព្រហ្មទណ្ឌ។

យោងតាមមាត្រា២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងយុត្តិធម៌សូម **ឯកឧត្តមព្រះរាជអាជ្ញា** ចាត់វិធានការផ្លូវច្បាប់ជាបន្ទាន់ និងតឹងរឹងបំផុតចំពោះអំពើប្រមាថចំពោះអង្គព្រះមហាក្សត្រខាងលើ ដោយអនុវត្តស្របតាមនីតិវិធីជាធរមាន។

សូម **ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**រដ្ឋមន្ត្រី**